sabay magz

A MONTHLY CAMBODIAN ENTERTAINMENT & LIFESTYLE GUIDE

FREE!

ISSUE #35/APRIL 2015

SCAN HERE FOR UPDATE INFOMATION

ស្នាមញញឹមនារីខ្មែរ

សៀមរាបជាប់លេខ ២
គោលដៅទេសចរណ៍ពិភពលោក

ឧបករណ៍យក្សបង្ហាញមុខនៅអង្គរសង្ក្រាន្ត

អត្ថន័យពិធីស្រង់ព្រះ

ស្លៀកពាក់បែបណាសមនឹងទៅវត្ត?

ឧបករណ៍ថ្មីប្រចាំខែមេសា

រៀនជំនាញ DJ គ្រាន់តែចំណាយពេល ១២ ម៉ោង

កម្មវិធីកម្សាន្តទាំង ៣ ថ្ងៃ

ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត

Editor's Note

សួស្តីមិត្តអ្នកអានទាំងអស់គ្នា!

ក្នុងឱកាសចូលឆ្នាំថ្មីនេះ Sabay Magzសូមជូនពរជ័យសិរីមង្គលគ្រប់ប្រការកើតមានដល់ ប្រជាជនខ្មែរគ្រប់រូប គ្រប់ទីកន្លែង !

សូមទេពធីតាព្រះនាមរាក្សសាទេវី ជួយបីបាច់ថែរក្សា ដីខ្មែរជាតិខ្មែរ ប្រជាពលរដ្ឋខ្មែរឲ្យជួបប្រទះតែនឹងភាពចម្រុងចម្រើន សុខសន្តិភាព មានជោគមានជ័យ គ្រប់ទិសទី!

ដោយក្តីគោរពពីខ្ញុំ

តុង

Issue
35
April 2015
facebook.com/SabayMagz

ស្នាមញញឹម យុវតីខ្មែរ ស្រស់ស្អាតចេញពីធម្មជាតិ ទំព័រ៤៦

Contents

ទំព័រ ០៤
អង្គរសង្ក្រាន្ត ២០១៥

ទំព័រ ១០
ចំនុចពិសេស របាំត្រុត

ទំព័រ ១២
គ្រឿងរណ្តាប់ ទទួលទេវតា

ទំព័រ ១៤
អត្ថន័យពិធី ស្រង់ព្រះ


ទំព័រ ២៦
រៀនជំនាញ DJ


ទំព័រ ៣១
ឈុត CINDERELLA

ទំព័រ ៣៦
Profile Yorng Pov


ទំព័រ ៣៨
ស្នាដៃគំនូរ ថៃ សាន

ទំព័រ ៤២
វិចិត្រករ កាណាដារ

ឧបករណ៍យក្ស នៅអង្គរសង្ក្រាន្ត ទំព័រ១៨

ឧបករណ៍ថ្មីៗខែមេសា ទំព័រ២៤

ការរៀបចំម្ហូប ទំព័រ៣០

SREYMOM PHAT
Sales Manager / Advertisement
089 777 670
phat.sreymom@cidc.com.kh
www.sabay.com.kh

ប្រធានផ្នែកគ្រប់គ្រង | Editor: លុក វណ្ណរង្គ Luok Vannrong
ផ្នែករៀបចំ និង រចនា | Graphic: លីវ ប៉ូលីន Liv Polin
អ្នកសម្របសម្រួល | Coordinator: លី សុផាត Ly Sophat
ផ្នែកថតរូប | Photographer: Pu Sem, Lorn Jadina , Avaha
ផ្នែកព័ត៌មាន | Writers: វិចទ័រ រ៉ូលីន
អាសយដ្ឋាន អគារ ៣០៨ មហាវិថីព្រះមុនីវង្ស រាជធានី ភ្នំពេញ បោះពុម្ពផ្សាយ៖ ប្រទេសកម្ពុជា, រោងពុម្ព៖ ព្រីន ម៉ាស្ទ័រ
ទំនាក់ទំនងការិយាល័យ Phone: (855) 023 228 000 /Fax: (855) 23 218 588
អ៊ីមែល៖ info@cidc.com.kh /www.sabay.com

iPhone 6 ជាជម្រើសដ៏ស័ក្តិសម
ជាមួយអ៊ិនធឺណិតល្បឿនលឿនបំផុតរបស់ Smart

មាននៅ Smart Shop ទូទាំងប្រទេស!

iPhone 6

ទំហំ	iPhone 6		iPhone 6 Plus	
	តម្លៃពេញ	តម្លៃបង់រំលស់ (12 ខែ)	តម្លៃពេញ	តម្លៃបង់រំលស់ (12 ខែ)
16 GB*	728 ដុល្លារ	70 ដុល្លារ/ខែ	828 ដុល្លារ	79 ដុល្លារ/ខែ
64 GB	848 ដុល្លារ	81 ដុល្លារ/ខែ	948 ដុល្លារ	91 ដុល្លារ/ខែ
128 GB	948 ដុល្លារ	91 ដុល្លារ/ខែ	1048 ដុល្លារ	100 ដុល្លារ/ខែ

* តម្រូវឱ្យបញ្ចូលលុយ 10 ដុល្លារ

ឥតគិតលុយ សេវា 4G LTE

ឥតគិតលុយ អ៊ិនធឺណិត 1 GB/ខែ រយៈពេល 1 ឆ្នាំ

ឥតគិតលុយ លេខពិសេស តម្លៃ 129 ដុល្លារ

ទទួលបាន ការធានា 1 ឆ្នាំ ពី Smart

ព័ត៌មានបន្ថែម: 888 ឬ 010 200 888

an axiata company
www.smart.com.kh

អង្គរសង្ក្រាន្ត ២០១៥ »
មានអ្វីពិសេសខ្លះ?

អង្គរសង្ក្រាន្តជាកម្មវិធីដែលរៀបចំឡើងដោយសហភាពសហព័ន្ធ យុវជនកម្ពុជា ក្រោមប្រធានបទ ការចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ។ ព្រឹត្តិការណ៍អង្គរសង្ក្រាន្តនេះរៀបចំឡើងដើម្បីអបអរសាទរឆ្នាំថ្មីប្រពៃណីជាតិខ្មែរជាមហាគ្រួសារតែមួយ រឹតបណ្តឹងចំណងមិត្តភាព សាមគ្គីភាពរវាងប្រជាជនខ្មែរនិងប្រជាជាតិលើសកលលោក ផ្តល់ឧកាសឲ្យភ្ញៀវទេសចរទាំងអស់បានស្វែងយល់បន្ថែមអំពីភាពរុងរឿង ភាពសម្បូរបែបនៃវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ប្រពៃណី ដោយមានការចូលរួមសម្តែង និងបង្ហាញអំពីល្បែងប្រជាប្រិយ របាំប្រពៃណី និងប្រជាប្រិយនានាដែលក្នុងនោះកម្មវិធីសំខាន់ៗ នឹងមានរៀបរាប់ក្នុងទំព័របន្ទាប់៕

Photo: Pu sem

ព្រះពុទ្ធសករាជព្រះសាសនា អតិក្កន្តាកន្លងទៅហើយបាន ២៥៥៨ ត្រឹមថ្ងៃ១៥កើត ខែពិសាខ លុះដល់ថ្ងៃ ១រោច ខែពិសាខ ឆ្នាំមមែ សប្តស័កតទៅចូលពុទ្ធសករាជ២៥៥៩។ សង្ក្រាន្តឆ្នាំថ្មីឆ្នាំមមែ នឹងចូលមកដល់នៅថ្ងៃអង្គារ ១១រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤មេសា គ.ស. ២០១៥ វេលាម៉ោង ១៤និង០២នាទី។ ពេលនោះ ព្រះអាទិត្យចេញពីមីនរាសី ទៅស្ថិតនៅមេសរាសី តាមផ្លូវគោវិថី គឺផ្លូវកណ្តាល ទើបមានទេពធិតាមួយព្រះអង្គជាមគ្គនាយិកាព្រះនាមរាក្សសៈទេវី ជាបុត្រីទី៣ នៃកបិលមហាព្រហ្ម គង់នៅចាតុម្មហារាជិកា ទ្រង់អម្ពរពណ៌ ខ្មៅ លំអនៅព្រះកាណ៌ដោយសៀត ផ្កាឈូក អភរណៈទ្រង់ពាក់កែវ មនោរា ភសស្សាហារទ្រង់សោយលោហិត ព្រះហស្តស្តាំទ្រង់ ត្រីសូល៍ ព្រះហស្តឆ្វេងទ្រង់ ធ្នូ ទ្រង់គង់លើខ្នង អស្សតរ(សេះ) ជាពាហនៈ។

ទើបនាំអស់ទេវបុត្រ ទេវធីតាទាំង មួយសែនកោដិហោះទៅកាន់ គុហាកែវធម្មាលីនាភ្នំកៃលាស ខេត្តហិមពាន្ត ជាទីតម្កល់ទុកព្រះសិរសាកបិលមហាព្រហ្ម ដែលតម្កល់ទុកលើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជ តាមផ្លូវព្រះអាទិត្យចរចំនួន៦០នាទី (២៤ម៉ោង)ទើបនាំយកទៅទុកនៅកន្លែងដើមវិញ។ រួចហើយ ទើបប្រជុំទេវបុត្រ ទេវធីតាទាំង មួយសែនកោដិ ចូលទៅស្រង់ទឹក អនោត្តមហាស្រះ ដែលមានទឹកហូរចេញពីបំពង់កែវដែលជាមាត់គោឧសភរាជទាំង៧ ត្រជាក់ក្សេមក្សាន្តព្រះរាជហឫទ័យ ហើយទើបនាំគ្នាចូលទៅសមាទានរក្សាសីលដោយសោមនស្សរីករាយគ្រប់ព្រះអង្គក្នុង ភគវតីសភាសាលាដែលវិស្សកម្មទេវបុត្រនិមិត្តថ្វាយដើម្បីបន្ទោបង់ អពមង្គលអោយជ្រះស្រលះហើយចំរើននូវសិរីសួស្តីជ័យមង្គលជន្នាយុឃីនយូរដល់ទេវតា និងមនុស្ស សត្វផងទាំងឡាយ តាំងពីឆ្នាំថ្មីចូលមកនេះ បានទូលំទូលាយសុខក្សេមក្សាន្តតរៀងទៅ៕

កម្មវិធីភូមិខ្ញុំ

រៀបចំឡើងជាស្លាបត្យកម្មរចនាបទខ្មែរ។ កម្មវិធីនេះមានផ្ទះ ៥ ខ្នង មានដូចជា ៖ ផ្ទះធ្វើគ្រឿងធ្វើរណ្តាប់បុណ្យ ផ្ទះភ្លេងបុរាណ ផ្ទះបង្អែមនំចំណី ផ្ទះតម្បាញ និងសាលាឆទាន។
តំបន់កម្សាន្ត មានការរៀបចំជាឆាកសម្តែងសិល្បៈ រាំកម្សាន្តដើម្បីស្វាគមន៍បងប្អូនដែលអញ្ជើញមកលេងក្នុងភូមិខ្ញុំ។
បង្ហាញពីទីប្រជុំជនក្នុងភូមិ តាមរយៈការរៀបចំបង្កើតឡើងជាផ្សារមួយបែបជនបទ ដែលមានការលក់ដូដូចជាចំណីអាហារខ្មែរ ឧបករណ៍ប្រើប្រាស់ និងវត្ថុអនុស្សាវរីយ៍ផ្សេងៗ។ ទីតាំង ៖ ទីលានជល់ដំរី

កម្មវិធីតំបន់ត្រជាក់ចិត្ត

ផ្តល់ការកម្សាន្តដែលបញ្ចូលសកម្មភាពសប្បាយៗជាច្រើន ដូចជា បរវកញ្ញាធ្លាក់ទឹក ឡើងសសរខ្លាញ់ ស្វាដណ្តើមពាងទូលក្អម រត់ប្រណាំងកាន់តងទឹកត្នោត និងតក់ៗពេញកែវជាដើម។ ទីតាំង៖ តំបន់ត្រពាំងសេស

កម្មវិធីនិម្មិតភូមិ

បង្ហាញពីការករកើតឡើងនៃក្រុងអង្គរ ដែលផ្តើមចេញពីភូមិសាស្រ្ត សាសនា ធនធានធម្មជាតិ បច្ចេកវិទ្យាទំនើបនៃសម័យបុរាណ ពាណិជ្ជកម្ម និងធនធានមនុស្ស។ ទីតាំង៖ មុខប្រាសាទអង្គរវត្ត

កម្មវិធីសាសនា

បង្ហាញពីទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនា របស់ប្រជាជនខ្មែរ។ សកម្មភាពមានដូចជា ពិធីបួងសួងសុំសេចក្តីសុខនៅប្រាសាទអង្គរវត្ត ពិធីទទួលទេវតាឆ្នាំថ្មីនៅប្រាសាទបាយ័ន ពិធីទៅវត្ត និងពូនភ្នំខ្សាច់ ជាចុងក្រោយគឺពិធីស្រង់ព្រះ។

កម្មវិធីល្បែងប្រជាប្រិយ

អ្នកចូលរួមទាំងអស់នឹងបានសប្បាយរីករាយលេងល្បែងប្រជាប្រិយជាច្រើនដូចជា បោះអង្គញ់ ចាប់កូនខ្លែង ចោលឈូង លាក់កន្សែង ទាញព្រ័ត្រ និងជាច្រើនទៀត។ ទីតាំង៖ មុខប្រាសាទអង្គរវត្ត និងតំបន់ត្រពាំងសេស។

កម្មវិធីរបាំបុរាណ ប្រពៃណី និងប្រជាប្រិយ

ផ្តល់ជូនទស្សនីយភាពរបាំខ្មែរ ១៩ របាំផ្សេងគ្នាដូចជា របាំសុវណ្ណមច្ឆា របាំទិវាប្រពៃ របាំកណ្តូបសេះ និងមួយចំនួនទៀត ដែលមានសម្តែងទាំង ៣ ថ្ងៃ។ បន្ថែមពីនេះ ការបង្ហាញពីមូលដ្ឋាននៃរបាំនិមួយៗក៏ត្រូវបានដាក់បញ្ចូលផងដែរ ដូច្នេះទាំងភ្ញៀវជាតិ និងអន្តរជាតិទាំងអស់អាចចូលរួមរៀនរបាំទាំងអស់នោះបានទាំងអស់គ្នា។ ទីតាំង៖ មុខកសិណាអង្គរខាងត្បូង ទីតាំងល្បែងប្រជាប្រិយ និងត្រពាំងសេស។

កម្មវិធីក្បួនដង្ហែអង្គរសង្ក្រាន្ត

ស្ថិតក្រោមប្រធានបទ « ក្បួនដង្ហែប្រជាជាតិ» ដែលបង្ហាញពីទស្សនាទាណនៃការថែររក្សារសន្តិភាព និងការផ្សះផ្សារជាតិ រក្សាបាននូវឯកភាពជាតិក្នុងភាពចម្រុះនៃវប្បធម៌ចែកជា ៥ ផ្នែក ៣៥ ផែន។ ការអបអរពិធីបុណ្យចូលឆ្នាំថ្មីដំណើរវិវត្តន៍នៃសំពត់លើបដិមាក្នុងសិល្បៈខ្មែរភាពចម្រុះនៃវប្បធម៌ និងពូជសាសន៍ក្បួនដង្ហែយុវជន

ទីតាំង៖ លានជល់ដំរី

កម្មវិធីគុនល្បុក្កតោ

បង្ហាញ និងផ្សព្វផ្សាយពីក្បាច់គុនបុរាណខ្មែរ « ល្បុកតោ » ជូនដល់ភ្ញៀវជាតិ និងអន្តរជាតិ។ សកម្មភាពពិសេសៗមានដូចជា ការសម្តែង និងនិទានពីក្បាច់គុនខ្មែរ ការហាត់សម ល្បុក្កតោ ពិព័ណ៌គ្រឿងសព្វាវុធ ការបង្ហាញភាពយន្តឯកសារនិងល្បែងកម្សាន្តផ្សេងៗពាក់ព័ន្ធក្បាច់គុនល្បុក្កតោ។ ទីតាំង៖ មុខកសិណាអង្គរ

នំអន្សមយក្សឆ្នាំនេះ គេរំពឹងថានឹងមានទម្ងន់ដល់ទៅ ៣.២ តោន ប្រហែលជាត្រូវចំណាយពេល ៤ ថ្ងៃដើម្បីចម្អិនក្រោមស្នាដៃចុងភៅ និងកូនកាំបិតប្រមាណ ១០០ នាក់ ដែលអាចនឹងឈានទៅបំបែកឯកត្តកម្មពិភពលោក។

Photo: Pu sem

កម្មវិធីគោមបណ្តែតទឹក

បួងសួងពរជ័យសុំសេចក្តីសុខចូលឆ្នាំថ្មី។ ចង្កៀងគោមតូចៗរាប់ពាន់បណ្តែតលើផ្ទៃទឹកក្នុងកសិណអង្គរវត្ត ដើម្បីបង្កើនសោភណភាពប្រាសាទប្រាសាទអង្គរវត្តកាន់តែស្រស់ស្អាតនៅពេលរាត្រី។ ទីតាំង៖ កសិណទឹកអង្គរវត្ត

កម្មវិធីប្រចាំថ្ងៃទី ១៤

- ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន
- កម្មវិធីភូមិខ្ញុំ
- កម្មវិធីក្បួនដង្ហែរអង្គរសង្ក្រាន
- ការសម្តែងល្បែងប្រជាប្រិយ គុនល្បុក្កតោ និងរបាំ (ទីលានជល់ដំរី)
- ពិធីកាត់នំអន្សមយក្ស
- ពិធីទទួលទេវតាឆ្នាំថ្មី
- ទាញព្រ័ត្រមិត្តភាពអង្គរសង្ក្រាន
- ដើងឯកញ៉ាំនុំអន្សមយក្ស
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- ពិធីបណ្តែតគោមបួងសួងសុំសេចក្តីសុខ
- កម្មវិធីមហោស្រពសិល្បៈបុរាណ

ថ្ងៃទី ១៥ មេសា

- ពិធីទៅវត្ត និងពូនភ្នំខ្សាច់
- កម្មវិធីរាំម៉ាឌីហ្សុន ២០១៥ នាក់
- កម្មវិធីក្បួនដង្ហែអង្គរសង្ក្រាន
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- កម្មវិធីមហោស្រពវប្បធម៌យុវជនអន្តរជាតិ

ថ្ងៃទី ១៦ មេសា

- ការប្រកួតអុកចត្រង្គអបអរសាទរអង្គរសង្ក្រាន ២០១៥
- ពិធីប្រគល់ជ័យលាភីរូបថត « អច្ឆរិយៈអង្គរសង្ក្រាន»
- ពិធីស្រង់ព្រះ
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីប្រកួតធ្វើម្ហូបអាហារ
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- កម្មវិធីតន្ត្រីអង្គរសង្ក្រានឆ្នាំ ២០១៥

កម្មវិធីប្រណាំងរទេះគោ ក្របី

ធ្វើឡើងដើម្បីរំឮកឡើងវិញនូវ វប្បធម៌ ប្រពៃណីខ្មែរក្នុងការប្រណាំងរទេះគោ ក្របី និងដើម្បីផ្សារភ្ជាប់ការប្រណាំងឧបករណ៍សម័យទំនើបក្នុងវិស័យកសិកម្ម និងលើកកម្ពស់ទឹកចិត្តស្រលាញ់បរិស្ថានកសិកម្ម ក្នុងសន្តាចចិត្តនៃប្រជាជនខ្មែរ។ សមាសភាពមាន រទេះគោ ៣០ រទេះក្របី ៣០ ត្រាក់ទ័រ ៣០ គ្រឿង និងគោយន្ត ៣០ គ្រឿង។ ទីតាំង៖ នៅតំបន់ពិព័រណ៍អង្គរឃ្យុងយូ។

ពិព័រណ៍ និងប្រកួតប្រជែងរូបថត

បង្ហាញពីរូបភាពនៃស្នាមញញឹមរាក់ទាក់នៃប្រជាជនខ្មែរ និងឆ្លុះបញ្ចាំងពីភាពសប្បុសប្បាយរបស់ប្រជាជនជាតិខ្មែរ និងការចូលរួមក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ។ ពិសេសជាងនេះគឺការផ្តល់ឱកាសដល់អ្នកជំនាញថតរូបជាច្រើនចូលរួមប្រកួតប្រជែងគ្នា តាមប្រធានបទដែលកំណត់។ ទីតាំង៖ នៅកសិណខាងមុខអង្គរវត្ត។

Photo: Pu sem

ចំនុចពិសេសរបាំត្រុដិ ដែលយុវវ័យមិនសូវដឹង

របាំប្រជាប្រិយដែលនិយមលេងជាងគេនាពេលចូលឆ្នាំគឺ របាំត្រុដិ។ ជាក់ស្តែងពាក្យថា ត្រុដិ នេះតែម្តងបកប្រែពីភាសាសំស្ក្រឹតមានន័យថាផ្តាច់ឬកាត់ផ្តាច់ ដែលសំដៅលើការកាត់ផ្តាច់ឆ្នាំចាស់និងអបអរសាទរការចូលមកដល់ឆ្នាំថ្មី។

របាំនេះមានអាយុកាលចំណាស់ ដោយបន្សល់ទុកមកតាំងពី ប្រទេសកម្ពុជាមិនទាន់ទទួលឥទ្ធិពលវប្បធម៌របស់ប្រទេសឥណ្ឌាមកម្ល៉េះ ហើយថែរក្សាបានដោយគង់វង្សដោយត្រកូលខ្មែរជំនាន់ដើម ដែលហៅថា សំរែ។ កាលពីជំនាន់បុរាណ វង់ត្រុដិរបស់ប្រជាជនសំរែនេះ តែងលេងរបាំត្រុដិថ្វាយព្រះរាជារៀងរាល់ពេលចូលឆ្នាំដើម្បីទទួលបានសេរី មង្គលឆ្នាំថ្មី ហើយទំនៀមទម្លាប់នេះ បានប្រារព្ធជាប់មកដល់បច្ចុប្បន្ន។ មានរឿងព្រេងនិងជំនឿជាច្រើនពាក់ពាន់នឹងដើមកំណើតនៃ របាំនេះ ប៉ុន្តែ មិនមានឯកសារនេះមួយអាចបញ្ជាក់ច្បាស់ឡើយថារបាំនេះត្រូវបានគេប្រារព្ធដើម្បីអ្វីឲ្យប្រាកដ។

តាមជំនឿរបស់អ្នកស្រុកបាត់ដំបង គេមានជំនឿថាពេលខ្លះយូរៗ ម្តងតែងតែមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក ហើយនាំមកនូវឧបទ្រពចង្រៃផ្សេងៗទើបគេបង្កើតឲ្យមានទម្លាប់ថាបើឃើញសត្វព្រៃចូលស្រុកកាលណាគេនាំ គ្នាប្រោះព្រំសុំពជ័យពីសត្វទាំងនោះវិញ។ ហេតុនេះហើយទើប របាំត្រុដិមានទាំងប្រើស ទន្សោង ក្ងោក ជាដើមដែលសុទ្ធសឹងជាសត្វព្រៃ មកបង្ហាញខ្លួនឲ្យអ្នកស្រុកបោះព្រំ ចងដៃអំបោះ និងឲ្យទានជាលុយកាក់ ដើម្បីរដោះគ្រោះឲ្យស្រេចៗ ទោះបីក្រោយមកមានសត្វព្រៃចូលស្រុកទៀតក៏មិនមានចង្រៃឧបទ្រពអ្វីកើតឡើងដែរ ព្រោះ គេបានប្រារព្ធពិធីតាំងពីដើមឆ្នាំទុករួចមកហើយ។

ប៉ុន្តែបើតាមជំនឿបែបសាសនាវិញ របាំត្រុដិ ជារបាំថ្វាយ អធិដ្ឋាន ទៅអាទិទេពដើម្បីសុំទឹកភ្លៀងទៅវិញ។ ប្រជាជនអាស៊ីនិយមចាត់ទុកសត្វក្ងោកតំណាងព្រះអាទិត្យ ហើយក្នុងការលេងរបាំត្រុដិនេះក៏មានការបង្ហាញពីសត្វក្ងោកដែរ ហើយប្រជាជនខ្មែរត្រូវការបន់ស្រន់ទៅព្រះអាទិត្យដើម្បីបានអំណោយទានជាទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ។ ហេតុនេះហើយទើបក្នុងការប្រារព្ធពិធីសុំទឹកភ្លៀងពេលជួបប្រទះគ្រោះរាំងស្ងួត ក៏មានការលេងរបាំត្រុដិក្នុងនោះផងដែរ។

មិនថារបាំត្រុដិនេះមានដើមកំណើតពិតពាក់ព័ន្ធនឹងជំនឿណាមួយឡើយ របាំត្រុដិជារបាំពិតរបស់ខ្មែរ បង្កើតឡើងនៅលើទឹកដីខ្មែរ មិនមានលាយឡំ ឬ ទទួលបានឥទ្ធិពលពីសាសនាឬទំនៀមទម្លាប់ប្រទេសដទៃ ដែលយើងគួរឲ្យតម្លៃ និងយកចិត្តទុកដាក់ដើម្បីថែរក្សាអរិយធម៌នេះ កុំឲ្យបាត់បង់។

One of the most performed and outstanding dance to celebrate Khmer New Year is Trot. "Trot" literally translated from Sanskrit meaning the end. It is to emphasize the end of a year passed and welcoming the upcoming of a new start.

Trot has been passed down from generations to generations even before the dawn of Indian cultural influence in Cambodia. Som Re, the aboriginal Khmer people who preserve this dance, made it a tradition to perform Trot for the royals every New Year and the tradition carry out until today. There are many myths and beliefs to explain why was Trot performed.

According to the locals in Battambong, once in while a wild animal from forest would come to the village, and that bring misfortunes. In order to neutralize the threat, the villagers will ask for blessings from the animals. Trot was a manifestation of this blessing as the dance depict many wild animals such as deer, peacock, bull, etc. The dance then was practiced every start of the year, so even if the wild animal comes to the village, the villagers are already blessed; hence, nothing bad will happen to them.

Religion wise, Trot was interpreted as a dance to ask for rain. Since Asian people usually assign peacock as the symbol of the sun, the dance featuring peacock was a dance to worship the sun god asking for enough rain for farming. Even the ceremony to ask for rain in drought disaster features Trot.

No matter what reasons to explain the creation of the dance, Trot is purely a Khmer heritage considering it was created with no influential of foreign tradition or culture that should be valued and paid immense attention to.

ស្លៀកពាក់បែបណា សមនឹងទៅវត្ត?

ការតុបតែងខ្លួនឲ្យបានត្រឹមត្រូវតាមពិធីបុណ្យទាន កាលៈទេសៈ ទីកន្លែង ក៏ជាទំនៀមទម្លាប់មួយរបស់ខ្មែរដែរ ដែលបង្ហាញពីការយល់ដឹង និងភាព ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ។ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ចំពេលត្រូវរៀបចំខ្លួនទៅវត្តលួម! យុវវ័យមានដឹងពីទំនៀមទម្លាប់ស្លៀកពាក់ទៅវត្តឬ អត់?

បើតាមការអនុវត្តរបស់ប្រជាជនខ្មែរជំនាន់ដើម បុរសនិងនារីពេលទៅវត្តគេស្លៀកសំពត់ចងក្បិន ជាមួយអាវកុតសម្រាប់បុរស និងសម្រាប់នារីគេពាក់អាវបំពង់និងពាក់នាក្រមា។ មកដល់សម័យបច្ចុប្បន្ន សំលៀកបំពាក់មានច្រើនជម្រើស ទំនើបនិងប្លែកៗជាងមុនប៉ុន្តែទោះ ជាសំលៀកបំពាក់ផ្លាស់ប្តូរ យើងមិនស្លៀកពាក់ដូចមុនក៏ដោយ ក៏នៅមានបម្រាមមួយចំនួនគួរចងចាំ ជៀសវាងស្លៀកពាក់ខុសបែបបទពេលទៅវត្ត។

អ្វីដែលគួរឲ្យចងចាំពេលមកជ្រើសរើសសំលៀកបំពាក់គឺ ភាពស្រគត់ស្រគំបិទបាំងដងខ្លួនបានល្អ។ វត្តជាទីសក្ការបូជារបស់ប្រជាជនខ្មែរយើង ដែលមានជំនឿលើព្រះពុទ្ធសាសនា ដូចនេះហើយសំលៀកបំពាក់ត្រូវបង្ហាញពីការគោរព និងចរិតលក្ខណៈសុភាពរាបសារ។ សំលៀកបំពាក់មួយចំនួនដែលគួរជៀសវាងមានដូចជា សំពត់ខ្លីខើចលើជង្គង់ អាវវាល ចំហមុខក្រោយផ្សេងៗ ឬ សំលៀកបំពាក់ដែលមានពណ៌ឆើតឆាយពេកជាដើម។ ពណ៌ដែលសមនឹងទៅវត្តគឺ ពណ៌ ស្រគាំ ស និងខ្មៅ។ អាកប្បកិរិយាមួយចំនួនដែលគួរប្រកាន់ភ្ជាប់ផងដែរ ពេលទៅវត្តគឺ ការដោះមួកពេលចូលបរិវេណវត្ត និងដោះស្បែកជើងពេលឡើងកុដិ និង សាលាឆាន់ជាដើម។ សម្រាប់ការផាត់មុខវិញ មិនត្រូវផាត់មុខច្រើនហួស បបូរមាត់ក៏មិនបាច់លាបឲ្យក្រហម ហ៊ឺហារដូចដើរលេងនោះទេ ព្រោះការទៅវត្តតម្រូវឲ្យយើងប្រកាន់យកចរិតសុភាពរម្យទម ជានិច្ច។

Sabay Magz សង្ឃឹមថាយុវវ័យទាំងអស់យល់ដឹងកាន់តែច្បាស់ពី ទំនៀមទម្លាប់ខ្មែរក្នុងការស្លៀកពាក់ ជៀសវាង ការប្រព្រឹត្តខុសបម្រាមនានា នាំឲ្យមានការរិះគន់ពីអ្នកដទៃ។

គ្រឿង រណ្តាប់ទទួល

ទេវតា នាំសិរីសួស្តីឆ្នាំថ្មី

ក្នុងថ្ងៃចូលឆ្នាំ ផ្ទះនីមួយៗតែងរៀបចំតុបតែង បោសសំអាតឲ្យមានសិរីជ័យមង្គល។ ដោយឡែក គេក៏មានត្រៀមនូវគ្រឿងរណ្តាប់ផ្សេងៗដើម្បីទទួលទេវតាឆ្នាំថ្មី ដែលគេមានជំនឿថានឹងចុះមកប្រោសព្រំមនុស្សសត្វឲ្យសុខសប្បាយ។

ទាក់ទិននឹងគ្រឿងរណ្តាប់ដែលខ្មែរនិយមដើម្បីទទួលអំណរទេវតាឆ្នាំថ្មី បើតាមលោកអាចារ្យ ហី លាភនៅវត្តកំសាន្ត មានប្រសាសន៍ថា ជាទូទៅគេដាក់របស់ទាំងនោះនៅលើតុ ឬ ហឹងដែលជាទីខ្ពស់ ហើយគ្រឿងទាំងនោះមានដូចជា បាយសីមួយគូ ប៉ាកឆាងមួយគូ ស្លាធម៌ ទឹកអប់ឆ្វេងស្តាំ ទៀនប្រាំធូបប្រាំ ទឹកមួយផ្តិលធំដាក់ចំកណ្តាលឬភេសជ្ជៈ ទៀនមួយគូអមសងខាង ផ្លែឈើ នំចំណី ផ្កាភ្ញីជាដើម។

លោកតាបញ្ជាក់ថា គ្រឿងទាំងអស់នេះមិនតម្រូវឲ្យត្រូវតែដាក់តាមហ្នឹងគ្រប់សព្វទេ គឺទៅតាមលទ្ធភាពនៃក្រុមគ្រួសារដែលមាន។ ផ្ទះអ្នកធូរធារគេអាចដាក់ដល់ទៅបាយសី៩ថ្នាក់ ៥ថ្នាក់អីក៏មាន។ ឯអ្នកមធ្យមអាចដាក់ត្រឹម៣ថ្នាក់ក៏បាន មិនប្រកាន់ឡើយ។ ចំណែកផ្លែឈើ ឬនំចំណីក៏ដូចគ្នា អ្នកមានលទ្ធភាពអាចដាក់ច្រើនមុខច្រើនចានតម្រៀបគ្នា តែអ្នកសមល្មមអាចដាក់តាមការគួរ មិនកំណត់ថា ត្រូវតែដាក់ច្រើន ធុំដុំទេ គ្រឿងរណ្តាប់ទាំងនោះសុទ្ធតែនាំមកនូវសិរីសួស្តីដូចគ្នា៕

អត្ថបទ៖ លឹម សុនា

អត្ថន័យពិធីស្រង់ព្រះក្នុងថ្ងៃចូលឆ្នាំ

ពិធីស្រង់ព្រះច្រើនធ្វើឡើងនៅថ្ងៃទី៣ ថ្ងៃចុងក្រោយនៃពិធីបុណ្យចូលឆ្នាំខ្មែរ ដែលត្រូវគេហៅថាថ្ងៃឡើងស័ក។ ពុទ្ធបរិស័ទទាំងជិតឆ្ងាយតែងមកវត្តអារាម ដើម្បីធ្វើពិធីនេះដោយមានទឹកលាយជាមួយផ្កាភ្ញីទឹកអប់ដើម្បីស្រោចស្រពដល់ព្រះបដិមាឬអ្នកមានគុណ អ្នកមានឋានៈខ្ពង់ខ្ពស់ជាង។

តាមប្រសាសន៍លោកតាអាចារ្យនៅវត្តកំសាន្ត នៅច្បារអំពៅ ថា ពិធីនេះប្រជាជនខ្មែរតែងប្រារព្ធធ្វើឡើងមិនដែលដាច់នៅពេលចូលឆ្នាំខ្មែរម្តងៗ និងមានជំនឿតៗគ្នាមកយូរហើយថា ស្រង់ព្រះទាំងព្រះបដិមាថ្ម និងព្រះរស់ សុទ្ធតែទទួលបានមកវិញនូវសេចក្តីសុខចម្រើន ត្រជាក់ត្រជុំដូចទឹកអ៊ីចឹងដែរ។

លោកតា ហី លាភ បន្តថា ទឹកតំណាងភាពត្រជាក់ ម្ល៉ះហើយនៅពេលស្រោចស្រពលើរាងកាយជនណាម្នាក់ហើយនឹងបានត្រជាក់ដែរ ។ ទាំងអ្នកស្រោចស្រពឲ្យគេ និងគេស្រោចឲ្យសុទ្ធតែសប្បាយចិត្ត ដោយជឿជាក់ថា នឹងទទួលបាននូវបុណ្យកុសលល្អទៅថ្ងៃខាងមុខ និងជាតិក្រោយ។ ក្នុងរយៈពេល៣៦៥ថ្ងៃ ពិធីចូលឆ្នាំមានត្រឹមតែ៣ថ្ងៃទេ នឹងចំរដូវដែលមានអាកាសធាតុក្តៅ (ខែចេត្រ) ដែលអត្ថន័យនៃពិធីនេះ មិនខុសអីពីការសំដែងដឹងគុណដល់អ្នកមានគុណនោះដែរ ព្រោះព្រះបដិមាសំដៅលើព្រះពុទ្ធដែលជាព្រះសំដែងធម៌ទេសនាប្រោសមនុស្សសត្វអស់កាលដ៏យូរដូច្នេះពុទ្ធបរិស័ទមកសំដែងគុណដោយធ្វើពិធីស្រង់ព្រះ លាងស្រោចដោយទឹកអប់ផ្កាភ្ញីជម្រះធូលីឲ្យត្រជាក់។ ចំណែកឯមាតាបិតា ឬចាស់ព្រឹទ្ធាចារ្យ ឬមានគុណ កូនចៅមកស្រោចទឹក ឬងូតទឹកជុសក្អែលឲ្យ ក៏ដើម្បីបង្ហាញពីការដឹងគុណ នឹងឲ្យបានត្រជាក់រីករាយដូចទឹក សប្បាយឆ្នាំចាស់ផ្លាស់ឆ្នាំថ្មីទាំងអស់គ្នា៕

អត្ថបទ៖ លឹម សុនា



កម្មវិធី ថ្ងៃទី ១៤

- ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន
- កម្មវិធីភូមិខ្ញុំ
- កម្មវិធីក្បួនដង្ហែអង្គរសង្ក្រាន
- ការសម្តែងល្បែងប្រជាប្រិយ
- គុនល្បុក្កតោ និងរបាំ (ទីលានជល់ដំរី)
- ពិធីកាត់នំអន្សមយក្ស
- ពិធីទទួលទេវតាឆ្នាំថ្មី
- ទាញព្រ័ត្រមិត្តភាពអង្គរសង្ក្រាន
- ជើងឯកញ៉ាំនុំអន្សមយក្ស
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- ពិធីបណ្តែតគោមបួងសួងសុំសេចក្តីសុខ
- កម្មវិធីមហោស្រពសិល្បៈបុរាណ

ថ្ងៃទី ១៥ មេសា

- ពិធីទៅវត្ត និងពូនភ្នំខ្សាច់
- កម្មវិធីរាំម៉ាឌីហ្សុន ២០១៥ នាក់
- កម្មវិធីក្បួនដង្ហែអង្គរសង្ក្រាន
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- កម្មវិធីមហោស្រពវប្បធម៌យុវជនអន្តរជាតិ

ថ្ងៃទី ១៦ មេសា

- ការប្រកួតអុកចត្រង្គអបអរសាទរអង្គរសង្ក្រាន ២០១៥
- ពិធីប្រគល់ជ័យលាភីរូបថត «
- អច្ឆរិយៈអង្គរសង្ក្រាន»
- ពិធីស្រង់ព្រះ
- កម្មវិធីប្រណាំងរទេះគោ និងក្របី
- កម្មវិធីប្រកួតធ្វើម្ហូបអាហារ
- កម្មវិធីការរាំជាក្រុមពញ្ញាក់អារម្មណ៍
- កម្មវិធីតន្ត្រីអង្គរសង្ក្រានឆ្នាំ ២០១៥

√ DO

- Only take amount of money you need with you
- Wear your back pack in the front
- The weather is hot so cover up with long sleeves, hat and glasses
- Bring along some water
- Bring map and schedule of event with you
- Park your car at hotel
- Wear comfortable shoes
- Bring some scarf or KROMA

X Don't

- Keep all your money in one place
- Wear heels during the long walk
- Bring along ID card / password when you tour around

អ្នកណាផ្តើមគំនិតផលិតឧបករណ៍
“យក្ស” ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្ត?

ការផលិតឧបករណ៍ទំហំធំ “យក្ស” ក្នុងព្រឹត្តិការណ៍អង្គរសង្ក្រាន្តឆ្នាំ២០១៥ កំពុងទទួលបានការចាប់អារម្មណ៍ពីសាធារណៈជន និងបណ្តាញផ្សព្វផ្សាយទាំងជាតិ និងអន្តរជាតិ ។ ឧបករណ៍ទាំងនោះមានជាអាទិ៍ បំពង់ទឹកត្នោតយក្ស មួកយក្ស អង្រុតយក្ស កន្ទ្រែងប្រហុកយក្ស និងការផលិតអន្សមយក្សកំពុងទទួលការ។ ប៉ុន្តែយើងនៅមិនដឹងថា តើអ្នកណាផ្តើមផលិតឧបករណ៍ទាំងអស់នេះទេ ?

ទាក់ទងនឹងការផលិតនេះ លោក សុខ សង្វារ ប្រធានក្រុមការងារអនុវត្តន៍ផែនការគ្រប់គ្រងទេសចរណ៍នៃអាជ្ញាធរអប្សរាបានថ្លែងថា ទាំងនេះគឺជាការផ្តើមគំនិតពីគម្រោង“ភូមិខ្ញុំ” ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហភាពសហព័ន្ធយុវជនកម្ពុជា។ គម្រោងនេះមានបំណងឆ្លុះបញ្ចាំងទិដ្ឋភាពការរស់នៅបែបខ្មែរ ក៏ដូចជាសិល្បៈវប្បធម៌ខ្មែរទៅកាន់ភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងឱកាសព្រឹត្តិការណ៍អង្គរសង្ក្រាន្ត។ ដូច្នេះឆ្នាំដំបូងគម្រោងបានតាំងបង្ហាញម៉ូដផ្ទះខ្មែរ រួមជាមួយឧបករណ៍ប្រើប្រាស់ចាំបាច់មួយចំនួនដូចជា រទេះគោ ទ្រូ និងកណ្តៀវជាដើម។

លោកបានបន្ថែមមកដល់ឆ្នាំនេះ គម្រោង “ភូមិខ្ញុំ” បានជួបពិភាក្សាគ្នា និងរិះរកអ្វីដែលថ្មី ប្លែក។ ដូច្នេះចុងក្រោយកិច្ចពិភាក្សាបានសម្រេចផលិតកន្ទ្រែងប្រហុក មួក បំពង់ទឹកត្នោត ព្រមទាំងអង្រុត ដែលមានទំហំធំ។ កន្ទ្រែងប្រហុក ឬអង្រុត ត្រូវបានពលរដ្ឋខ្មែរមួយចំនួនមិនស្គាល់ និងប្រើប្រាស់យ៉ាងដូចម្តេចនោះទេ។ “បើសិនយើងធ្វើក្នុងទំហំធម្មតា មិនអាចទាក់ទាញការចាប់អារម្មណ៍នោះទេ។ នេះគឺជាចំណុចគន្លឹះរបស់យើង...យើងមានបំណងលើកតម្កើងសិប្បកម្មខ្មែរ។ គម្រោង “ភូមិខ្ញុំ”បានចាប់ផ្តើមតាំងពីចុងឆ្នាំ២០១៤ ដោយចុះទៅកាន់ភូមិប្រណាក ដើម្បីឱ្យពូៗ យាយៗ អាចផលិតឧបករណ៍ទាំងនេះ ពួកគាត់ថាមិនធ្លាប់ធ្វើ និងមិនដឹងធ្វើម៉េចទេ”។

បើតាមលោក សុខ សង្វារ គម្រោង “ភូមិខ្ញុំ” កំពុងសហការណ៍ជាមួយគណៈកម្មាធិការអូឡាំពិក និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដាក់បញ្ចូលឧបករណ៍ទាំងអស់នេះ ក្នុងឯកទកម្មថ្នាក់ជាតិ។

ឧបករណ៍ទំហំធំទាំងនោះមាន ទំហំធំទាំងនោះមាន កន្ទ្រែងប្រហុកយក្សទម្ងន់១៥០គីឡូក្រាម មានបណ្តោយ ៦,១ ម៉ែត្រ ផ្ទុយពីកន្ទ្រែងប្រហុកធម្មតាដែលទម្ងន់៧៥ក្រាម និងបណ្តោយ៤សង់ទីម៉ែត្រ។ រយៈពេលផលិតមានចំនួន៧ថ្ងៃ និងមានអ្នកផលិតចំនួន១១នាក់។ បំពង់ទឹកត្នោតយក្ស មានកំពស់១,២ម៉ែត្រ និងផ្ទុកទឹកត្នោតបាន១៥លីត្រ មួកយក្សទម្ងន់ជិត២០០គីឡូក្រាម ផ្ទុយពីមួកធម្មតាទម្ងន់៩០ក្រាម។ អ្នកផលិតចំនួន១១នាក់ ហើយរយៈពេលនៃការផលិតមានចំនួន២៣ថ្ងៃ អង្រុតយក្សទម្ងន់៣៥០គីឡូក្រាម ផ្ទុយពីអង្រុតធម្មតា១,២គីឡូក្រាម។ រយៈពេលនៃការផលិតអង្រុតយក្សចំនួន២៤ថ្ងៃ និងមានអ្នកផលិតចំនួន១១នាក់៕

Photo: Lorn Ja Dina

សៀមរាបគ្រងលេខ២
គោលដៅទេសចរពិភពលោក ២០១៥

សៀមរាប ដែនដី ប្រាង្គប្រាសាទមរកតបូរាណខ្មែរ នៅតែឡើងកូដគឺជាគោលដៅលេចធ្លោសម្រាប់ទេសចរ២០១៥នេះ។ Tripadvisor ទើបបញ្ចេញចំណាត់ថ្នាក់គោលដៅទេសចរណ៍កំពូលៗ លើពិភពលោក ដែល ខេត្តសៀមរាប ស្ទើរតែក្រសោបតំណែងលេខមួយទៅហើយ គឺប្រជាប្រិយភាពរបស់ សៀមរាបកម្ពុជា នៅក្រោមតែទីក្រុង Marrakesh ប្រទេសម៉ូរ៉ាកូ តែមួយគត់។ ទីក្រុងហាណូយរបស់វៀតណាម ឈរលេខរៀងទី៤ ចំពេល បាងកក របស់ថៃ ស្ថិតនៅចំណាត់ថ្នាក់លេខ១៩។ ចំណាត់ថ្នាក់នេះសម្រេចបានតាមរយៈការបញ្ចេញមតិរបស់ភ្ញៀវទេសចររាប់លាននាក់ ដែល មតិគាំ ទ្រ ខេត្តសៀមរាប កម្ពុជាភាគច្រើនស្ញើចសរសើរដល់ប្រាង្គប្រាសាទជាច្រើនដែលមានក្បាច់ចម្លាក់លើសសរល្អដាច់គេ ដែលពិសេសបំផុតនោះគឺចម្លាក់លើប្រាង្គប្រាសាទខ្មែរដែលបង្ហាញ ពីរឿងព្រេង ជំនឿសាសនា និងវប្បធម៌ អរិយធម៌របស់ខ្មែរបុរាណ។ ក្នុងនោះដែរ ប្រាង្គប្រាសាទនៅខេត្តសៀមរាបដែលមានប្រជាប្រិយភាពជាងគេគឺប្រាសាទអង្គរធំ បន្សល់ទុកតាំងពីសតវត្សទី១២ ដែលជា រាជធានីចំណាស់មួយ បង្ហាញពី ឥទ្ធិពល សក្តានុពលខ្មែរកាលពីយូរលង់ណាស់មកហើយ។

Tripadvisor recently released the list of 25 top destination of the world 2015, with no doubt the renowned land of Siem Reap make up the list, landing second only to Marrakesh, Morocco.

The rank was decided by the votes of millions and millions of travelers. Most of the supporters of Siem Reap, Cambodia highly praised the complex structure of the temples, not to mention the the sculpture on the walls of each temples that tell the stories of Khmer folktales, belief and religion that express deep-rooted ancient culture. The most popular temple is Angkor Thom, the royal city of Angkor that flaunt Khmer influence and power from the 12th century.

ចូលឆ្នាំខ្មែរឆ្នាំនេះ តម្លៃឡានឈ្នួល

ឡើងថ្លៃដូចសព្វដងអត់ហ្នំ!

ឆ្នាំណាក៏ដូចឆ្នាំណាដែរ ឲ្យតែចូលដល់រដូវបុណ្យទានធំៗ តម្លៃឡានឈ្នួលដឹងតែលោតឡើងថ្លៃ គ្មានត្រាប្រណី បើទោះបីជាមានការអំពាវនាវខាងសាលារាជធានីភ្នំពេញយ៉ាងណាក៏ដោយ។ បញ្ហានេះ ជាហេតុធ្វើឲ្យមានការរអ៊ូរទាំពីសំណាក់អ្នកធ្វើដំណើរទៅលេងស្រុកកំណើតគ្រប់ៗគ្នា។

ចុះសម្រាប់រដូវបុណ្យចូលឆ្នាំខ្មែរឆ្នាំនេះវិញ តើតម្លៃឡានឈ្នួលទៅតាមបណ្តាខេត្ត-ក្រុង នឹងឡើងថ្លៃ ដូចសព្វមួយដងដែរអត់?

កញ្ញា ភារី កម្មការិនីមួយរូប ធ្វើការនៅមុំចោមចៅ ប្រាប់ឲ្យដឹងថា៖ “សឹងថាជាទម្លាប់ទៅហើយបង រឿងថ្លៃឡានឈ្នួលឡើងថ្លៃនោះ តែធ្វើម៉េចបើនៅតែចាំជ្រេរកតម្លៃថោក ច្បាស់ជាគ្មានឡានជិះទៅស្រុកទេ ព្រោះរដូវចូលឆ្នាំខ្មែរអីចឹង មិនថាឡានតូច ឬឡានធំទេ ដំឡើងថ្លៃទាំងអស់ហ្នឹង”។

ស្រដៀងគ្នានេះដែរ យុវជន ឆោម វិបុល អាយុ២៦ឆ្នាំ មានស្រុកកំណើតនៅឯខេត្តបាត់ដំបង លើកឡើងពីបញ្ហាឡានឈ្នួលសម្រុកឡើងថ្លៃ ខែចូលឆ្នាំថា ថ្លៃឡានឡើងរាល់តែឆ្នាំហ្នឹង បើមិនឡើងទើបចម្លែក។

យុវជនរូបនេះ សង្កត់ធ្ងន់ទៀតថា៖ “បើថាឡើងថ្លៃក៏ឡើងទៅចុះ ធ្វើម៉េចយូរៗមានឱកាសម្តង តែសូមឲ្យយកថ្លៃល្មមៗទៅបានហើយ លេងដល់ថ្នាក់ឡើង ២ ៣ដងលើសតម្លៃធម្មតា ដូចជាជ្រុលពេកហើយ”។

តើការឡើងថ្លៃរថយន្តជាកំហុសរបស់ម្ចាស់ឡាន ឬមានហេតុផលអ្វីផ្សេង?

ជួបជាមួយតៃកុងឡានតួរីសជើងចាស់មួយរូបនៅខេត្តតាកែវ លោក ចិន គឹមសៀង អាយុ ៤៥ ឆ្នាំ បានលើកឡើងពីហេតុផល នៃការកើនឡើងថ្លៃឡានឈ្នួលថា៖ “ខ្ញុំជឿថា ឲ្យតែមានបុណ្យទានអីចឹង! ម្ចាស់រថយន្តឈ្នួលសឹងតែទាំងអស់ ច្បាស់ជាមានការទារថ្លៃលើសតម្លៃដើមខ្លះហើយ ធ្វើម៉េចគ្នារកបានតែប៉ុន្មានថ្ងៃនេះឯង ណាមួយថ្លៃសាំងពេលនោះក៏ឡើងថ្លៃដែរ“។

តៃកុងឡានរូបនោះ បន្ថែមទៀតថា៖ « បើមិនឲ្យខាងម្ចាស់ឡានឡើងថ្លៃខ្លះក៏មិនកើតដែរ។ អ្នកខ្លះឃើញគ្នាដឹងម៉ូយពេញឡាន ហើយទារថ្លៃលើសបន្តិចចេះតែស្រែក តែកុំភ្លេចថា ពីរ បីថ្ងៃនោះតៃកុងឡានគ្នាដាក់ម៉ូយបានតែពេលចេញពីក្រុងទេ ដល់ពេលចូលក្រុងមកយកម៉ូយវិញ គឺអត់មានអ្នកជិះទេ ណាមួយត្រូវបង់ថ្លៃតាមផ្លូវឲ្យប៉ូលិសតាមផ្លូវទៀតផង”។

ពាក់ព័ន្ធនឹងតម្លៃឡានឈ្នួលឡើងថ្លៃរដូវបុណ្យទាននេះដែរ លោក ឡុង ឌីម៉ង់ មន្ត្រីនាំពាក្យសាលារាជធានីភ្នំពេញ បានប្រាប់ឲ្យដឹងដែរថា៖ រឿងឡានឡើងថ្លៃនេះ មិនមែនជាលើកទី១ទេ ហើយខាងសាលាក្រុងក៏បានចាត់វិធានការ និងធ្វើការអំពាវនាវដល់ក្រុមហ៊ុនរថយន្តក្រុង និងឡានតាក់ស៊ី កុំឲ្យឡើងថ្លៃខ្លាំងពេកដែរ។

ទោះបីជាយ៉ាងណា លោក ថាខាងសាលារាជធានីភ្នំពេញ មានសមត្ថកិច្ចអាចត្រឹមតែរឹតបន្តឹងការធ្វើចរាចរណ៍ខុសច្បាប់ ដូចជាការដឹកជញ្ជូនលើសចំណុះ ផ្ទុកមនុស្សច្រើនពេកតែប៉ុណ្ណោះ ពោលគឺខាងលោកមិនអាចទៅកំណត់តម្លៃឡានឈ្នួលបានឡើយ។

អ្នកនាំពាក្យរូបនេះ ក៏បានអំពាវនាវដែរថា៖ “សម្រាប់បុណ្យចូលឆ្នាំខ្មែរ ឆ្នាំនេះសាលារាជធានីនៅតែអំពាវនាវជាដដែលៗ សូមម្ចាស់ឡានឈ្នួល ឡានក្រុងគ្រប់ប្រភេទ មេត្តាកុំឡើងថ្លៃខ្លាំងពេក គិតដល់បងប្អូន កម្មករ កម្មការិនីយើងខ្លះផង។ ម៉្យាងទៀត សូមមេត្តាកុំដឹកលើសអ្វីដែលច្បាប់បានកំណត់”៕

អត្ថបទ៖ ឃិន សំបូរ

អូរត្រេះ ឆ្នេរសមុទ្រស្ងប់ស្ងាត់

បរិយាកាសល្អបរិសុទ្ធ

អូរត្រេះជាឆ្នេរសមុទ្រមួយនៃក្រុងព្រះសីហនុនៅភាគខាងត្បូងនៃឆ្នេរអូរឈើទាល។ លាតសន្ធឹងតាមបណ្តោយសមុទ្រនៃក្រុងព្រះសីហនុ ឆ្នេរ អូរត្រេះមានប្រវែងដល់ទៅ៣គីឡូម៉ែត្រ។ អ្វីដែលដែលចែកដាច់ឆ្នេរអូរត្រេះពីឆ្នេរដទៃនៅក្រុងព្រះសីហនុ គឺភាពស្ងប់ស្ងាត់មិនងាយនឹងរកបានឡើយនៅឆ្នេរផ្សេងៗ ដោយមានភ្ញៀវទេសចរច្រើន។ សម្រាប់ឆ្នេរអូរត្រេះវិញ ហាក់បីដូចជានៅដាច់ដោយឡែក ព្រោះប្រជាជនខ្មែរមិនសូវពេញនិយមទេ មានភាគច្រើនតែភ្ញៀវបរទេសប៉ុណ្ណោះដែលពេញនិយមទៅសម្រាកលំហែកាយនៅទីនោះ។ ថ្វីត្បិតអូរត្រេះ មិនសូវមានសភាពកុះករក៏ពិតមែន ប៉ុន្តែបើបានទៅដល់ធានាថាមិនអផ្សុកឡើយព្រោះនៅទីនោះមានសេវាកម្មជិះស្គីលើទឹកលេងជាច្រើនប្រភេទដែលក្នុងនោះមាន៖

ការជិះស្គី ប្រភេទHurricane Wind-surfing តម្លៃ US$8ក្នុងមួយម៉ោង
ការជិះស្គីប្រភេទ Skim Boarding និង Bungee Skim Boarding

ការជិះទូក Sea Kayaks តម្លៃ US$4 ទៅ US$៦ ក្នុងមួយម៉ោង

ប្រសិនបើមិត្តៗ យុវវ័យចង់កម្សាន្តលេងនៅសមុទ្រដែលមានលក្ខណៈរ៉ូមែនទិកស្ងប់ស្ងាត់ លើកក្រោយសាកល្បងទៅឆ្នេរអូរត្រេះម្តងមើល!

រថយន្ត MG3 ជាស្ទីលដ៏អស្ចារ្យនៃប្រភេទរថយន្តខ្នាតតូច

រថយន្ត MG3 Lux 2015 ស៊េរីថ្មី គឺមានវត្តមាននៅក្នុងទីផ្សាប្រទេសកម្ពុជាហើយ

ជាមួយនឹងការរចនាដ៏ពេញនិយមឆ្នូតកែមស្ព័ររបស់វានិងជាសុខភាពនៅផ្នែកខាងក្នុង ទាំងនេះហើយបានធ្វើអោយរថយន្ត MG3 ហាក់ដូចជារចនាឡើងសម្រាប់លក្ខខណ្ឌផ្លូវនៃទីក្រុងភ្នំពេញ ។

រថយន្ត MG3 គឺបានជះឥទ្ធិពលលើទីផ្សាចក្រភពអង់គ្លេសរួចជាស្រេចទៅនឹងអត្រាកំណើនកើនឡើងនៃទីផ្សាររបស់ខ្លួន ។ ក្នុងការគ្រប់គ្រង និងរបៀបរស់នៅនៃចក្រភពអង់គ្លេស MG គឺកំពុងបន្តស្វែងរកដើម្បីផ្តល់នូវបរិយាកាសថ្មីៗទៅដល់លើ brand របស់ខ្លួន និងសម្លឹងមើលលើការប្រើប្រាស់ក្នុងភាពជោគជ័យដ៏អស្ចារ្យនៃ រថយន្ត MG6 ក្នុងឆ្នាំ2013 ។

រថយន្ត MG3 នៅចក្រភពអង់គ្លេស ជាប្រភេទរថយន្តដែលមានភាពសប្បាយរីករាយក្នុងការបើកបរ ជាមួយនឹងជម្រើសដ៏ល្អមួយក្នុងតម្លៃដ៏សមរម្យ បានធ្វើអោយអ្នកដែលនិយមរថយន្តខ្នាតតូចទទួលការចាប់អារម្មណ៍ជាខ្លាំង ។ តើមានអ្វីភ្ញាក់ផ្អើលជាសាធារណៈនៅចក្រភពអង់គ្លេស នោះគឺ កម្រិត និងជម្រើសផ្ទាល់ខ្លួនដែលអាចរកបាន។ MG Cambodia ផ្តល់នូវឯកសិទ្ធិដូចគ្នាដូចដែលពួកគេបាននាំចូលគឺ រថយន្តប្រភេទ full options ជាមួយ ប្រព័ន្ធ Hi-fi 360ដឺក្រេ sunroof ទំហំកង់14 អ៊ីញ ដែលមានលទ្ធភាពក្នុងការផ្លាស់ប្តូទៅទំហំ 16អ៊ីញ ហើយក៏អាច ភ្ជាប់ iPhone និង smartphone បានគ្រប់ពេលវេលា ។

ជាមួយនឹងតំលៃត្រឹមតែ26800$ ហើយតំលៃនេះអាចពិភាក្សាគ្នាបានផងដែរ នៅពេលដែលលោកអ្នកអញ្ជើញមក showroom របស់យើងខ្ញុំដោយផ្ទាល់ ។ មួយវិញទៀតរថយន្ត MG3 Lux 2015 នេះជាប្រភេទរថយន្តដែលមានតំលៃសមរម្យបំផុតនៅក្នុងទីផ្សាប្រទេសកម្ពុជា ។ ជាការពិតណាស់ រថយន្តម៉ាក KIA Picantoមានតំលៃទាបជាងរថយន្ត MG3 Lux 2015 ប៉ុន្តែទំហំម៉ាស៊ីនរបស់វាគឺត្រឹមតែ 1.0l តែប៉ុណ្ណោះរីឯទំហំម៉ាស៊ីនរបស់រថយន្ត MG3 វិញគឺមានទំហំរហូតដល់ 1.5l. យោងទៅតាមប្រសាសន៍លោកនាយកផ្នែកទីផ្សាររបស់ ក្រុមហ៊ុន MG Cambodia, លោក ពុំ សុរិយាបាន អោយដឹងថា អតិថិជន កម្ពុជា គឺកុំពុងស្វែងរកប្រភេទរថយន្តដែលល្អសំរាប់គ្រួសាររបស់ពួកគាត់ដែលវាមិនត្រឹមតែជារថយន្តសំរាប់បើកបរនៅក្នុងទីក្រុងតែប៉ុណ្ណោះទេពួកគាត់ក៏ត្រូវការរថយន្តដែលមានសមត្ថភាព គ្រប់គ្រាន់ក្នុងការផ្តល់ឱកាសអោយពួកគាត់បានទស្សនាខេត្តព្រះសីហនុ ឬ ខេត្តសៀមរាប នាចុងសប្តាហ៍ដោយសប្បាយរីករាយ ។ លើសពីនេះទៅទៀត ក្រុមគ្រួសារ ហើយនឹងមិត្តភក្តិក៏អាចរីករាយជួយជាមួយនឹង កន្លែងទុកឥវ៉ាន់ ដែលមានទំហំធំទូលាយនៅផ្នែកខាងក្រោយនៃរថយន្ត ។ និយាយរួមមករថយន្ត MG3 Lux 2015 មានឱកាសដ៏ល្អមួយ ដើម្បីទទួលបានភាពជោគជ័យនៅលើទីផ្សារកម្ពុជា ។ នេះគ្រាន់តែជាការផ្តល់ពត៌មានប៉ុណ្ណោះ ដើម្បីអោយកាន់តែច្បាស់ លោកអ្នកអាចអញ្ជើញមកទស្សនាផ្ទាល់នៅ showroom ដើម្បីធ្វើការពិនិត្យអោយជាក់ច្បាស់ដោយខ្លួនលោកអ្នកផ្ទាល់ ។ អ្វីដែលពួកយើងបានឃើញនោះគឺ រថយន្តនេះពិតជាមានសក្តានុពលយ៉ាងអស្ចារ្យ ។ ប្រសិនបើលោកអ្នកចង់ដឹងកាន់តែច្បាស់ រថយន្ត MG3 X Ross ដែលជារថយន្តប្រភេទ SUV ធុនតូច នឹងត្រូវបាននាំចូលក្នុងពេលឆាប់ៗនេះ ។

Advertorial

#207, Russian Blvd ,Phnom Penh 023 882 552

PEBBLE TIME

Pebble ជានាឡិកាឆ្លាតវៃដំបូងបំផុតដែលអាចភ្ជាប់បានជាមួយប្រព័ន្ធដំណើរការiOS និង Andriod។ឥលូវនេះPebble បានត្រលប់មកម្តងទៀតហើយជាមួយ Pebble Time ដែលចំណុចពិសេសរបស់ Pebble Time គឺមានភ្ជាប់ជាមួយ microphoneដែលធ្វើឲ្យមានការងាយស្រួលក្នុងការឆ្លើយតបសារmessage និងEmail ជាដើម។ តម្លៃចាប់ពី $199 ឡើងទៅ។ ពណ៌ ស ខ្មៅ ក្រហម

PODO

– The First Stick and Shoot Camera

Podo ជាកាមេរ៉ាដែលមានផ្នែកខាងក្រោយជាជ័រស្អិតដែលអាច បិតជាប់នឹងជញ្ជាំង និងមានភ្ជាប់ Bluetooth ជាមួយទូរស័ព្ទរបស់អ្នកដើម្បីបង្ហាញ Preview ថាតើរូបអ្នកនឹងថតចេញមកបានស្អាតប៉ុណ្ណា ត្រូវ Angle ដែលអ្នកចង់បាន ឬអត់ ជាដើម។ តម្លៃ ចាប់ពី $99 ឡើងទៅ។

DNA PRO 2.0

MONSTER HEADPHONES

ជាកាសសេរីថ្មីរបស់ក្រុមហ៊ុនMonster ដែលបង្កើតឡើងពិសេសសម្រាប់ ទូរស័ព្ទ និងបច្ចេកវិទ្យារបស់ក្រុមហ៊ុន Apple តែមួយគត់។ DNA Pro 2.0 Monster Headphonesមាន voice cancellation system ដែលទប់មិនឲ្យសំឡេងពីbackgroundលឺឡើយពេលកំពុងប្រើកាសនេះធ្វើឲ្យអ្នកប្រើប្រាស់ទទួលបានបទពិសោធស្តាប់ចម្រៀងបានលឺច្បាស់ល្អ និងbluetoothចាប់បានចម្ងាយដល់ទៅ15ម៉ែត្រ។តម្លៃចាប់ពី $129 ឡើងទៅ។
ពណ៌ ស ខ្មៅ

MacBook ជំនាន់ថ្មីមួយនេះត្រូវបានរចនាឡើងដោយមានទំហំអេក្រង់ ១២ អ៊ីញ LED-backlit display ប្រភេទ Retina display ជាមួយនឹងបច្ចេកវិទ្យា IPS កម្រិត Resolution 2304 x 1440 pixels។ ពិសេសទៅទៀតនោះ វាមានកម្រាស់ត្រឹមតែ ១៣,១ម.ម ស្ដើងជាង MacBook Air ដល់ទៅ២៤ភាគរយ និងមានទម្ងន់ត្រឹមតែ 0,៩0 គ.កតែប៉ុណ្ណោះ ។

ជាមួយនឹងការរចនាថ្មីនេះដែរ MacBook ទំហំ១២អ៊ីញនេះមាន Keyboard ធំងាយស្រួលក្នុងការវាយ និងមាន Force Touch trackpad ដែលភ្ជាប់មកជាមួយបច្ចេកវិទ្យា Force Click។ លើសពីនេះ ក្រុមហ៊ុន Apple ក៏បានកាត់បន្ថយចំនួនរន្ធ Port ដោយដាក់មកជាមួយរន្ធ Port ថ្មី USB-C ដែលអាចប្រើបានជាមួយនឹងប្រភេទខ្សែរផ្សេងៗគ្នាដូចជា VGA, HDMI និង DisplayPort។ ចំណែកឯថាមពលថ្មវិញក៏អាចប្រើបានយូរជាងម៉ូដែលមុនៗដែរ។

MacBook ជំនាន់ថ្មីនេះគឺមានពីរប្រភេទ ដោយមួយមាន CPU ល្បឿន 1.1GHz Intel Core M, ក្រាហ្វិកIntel HD 5300, RAM ទំហំ 8GB, និង SSD ទំហំ 256GB ដោយលក់ក្នុងតម្លៃ ១២៩៩ដុល្លារ និងមួយទៀតនោះគឺត្រូវបានបំពាក់ដោយ CPU ល្បឿន 1.2GHz ជាមួយទំហំ SSD 512GB លក់ក្នុងតម្លៃ ១៥៩៩ដុល្លារ។

MacBook ទំហំ ១២ អ៊ីញនេះនឹងចាប់ផ្ដើមដាក់លក់នៅថ្ងៃទី ១0 ខែមេសា និងមានបីព័ណ៌សម្រាប់ជ្រើសរើស គឺព័ណ៌ប្រាក់ ព័ណ៌មាស និង ព័ណ៌ប្រផេះ៕

HP SPECTRE X360 NOTEBOOK

HP ចេញ Notebook សេរីថ្មី ប្រើប្រាស់ប្រព័ន្ធដំណើរការចុងក្រោយបំផុត Core i7 និងអាចកាច់បង្វិលអេក្រង់បានមួយជុំពេញគឺ 360 ដឺក្រេ ធ្វើឲ្យអ្នកប្រើប្រាស់អាចយកHP Spectre x360 Notebook មកប្រើប្រាស់ជាកុំព្យូទ័រក៏បាន និងជា Tablet ក៏បាន។ តម្លៃ $1100 ។
ទំហំ 13inches / កម្រាស់ 16mm / ទម្ងន់ 1.5kg

OS-AGNOSTIC MOBILE KEYBOARD

Microsoft ចេញ Wireless Keyboard ដែលប្រើប្រាស់ Bluetooth ជំនាន់ក្រោយដែលកាន់ទាក់ទាញជាងមុនដោយអាចបត់ជា២កំណាត់បានធ្វើអោយវាមានរាងតូចងាយស្រួលដាក់តាមខ្លួនប្រើប្រាស់ជាមួយទូរស័ព្ទ និង Tablet ជាដើម។ តម្លៃ $80។

រៀនជំនាញ DJ ចំណាយពេល

ត្រឹម១២ម៉ោងប៉ុណ្ណោះ !

Cambodia DJ Academy ជាសាលាបង្រៀនជំនាញ DJ តែមួយគត់នៅកម្ពុជា បង្កើតឡើងដោយមានការសហការរបស់ក្រុមហ៊ុន KTH និងក្រុមហ៊ុន Pioneer។ ជំនាញ DJ ដែលបង្រៀននៅ Cambodia DJ Academy នេះគឺបង្រៀនឲ្យចេះបញ្ចូលចម្រៀងច្រើនបទចូលគ្នា ធ្វើយ៉ាងណាឲ្យបទទាំងនោះត្រូវចង្វាក់គ្នាទើបស្តាប់ទៅពីរោះប្លែក។

នាយកសាលា Cambodia DJ Academy គឺ លោក Anthony Whyte បាននិយាយប្រាប់ Sabay Magz ថា នរណាៗ ក៏អាចរៀនជំនាញនេះបានដែរ មិនថាសម្រាប់តែអ្នកចង់ចាប់យកជំនាញ DJ ជាអាជីពនោះទេ។ សម្រាប់យុវវ័យមួយចំនួនដែលចូលចិត្តតន្ត្រី ចូលចិត្តសិក្សាលើអ្វីដែលថ្មី អាចមកសិក្សាជំនាញ DJ បាន ចំណាយពេលត្រឹមតែ១២ម៉ោងប៉ុណ្ណោះក្នុងថ្នាក់ចាប់ផ្តើមដំបូងរបស់ Cambodia DJ Academy ដែលបន្ទាប់ពីបញ្ចប់ថ្នាក់ចាប់ផ្តើមនេះ អ្នកនឹងមានជំនាញ mix ភ្លេងមិនចាញ់អ្នកអាជីពឡើយ! Mix ភ្លេងបានមិនថាលើ Computer ឬលើម៉ាស៊ីន mix ភ្លេងដូច DJ មែនទែនអីចឹង តែបើចង់ចាប់យកជាជំនាញសិល្បៈតែម្តង ក៏អាចបន្តទៅថ្នាក់ Intermediate និង Advance បន្តទៀត។

ជាទូទៅប្រជាជនខ្មែរច្រើនតែ លាយលំការលេងចម្រៀងDJ និងការកម្សាន្តក្នុងក្លឹបជាទង្វើរបស់ក្មេងទំនើង ចូលចិត្តតែដើរលេងសប្បាយដាច់យប់។ ចំពោះបញ្ហានេះ លោក Anthony បានបកស្រាយថា “ គោលបំណងរបស់ Cambodia DJ Academy គឺចង់ឲ្យប្រជាជនខ្មែរងាកមើលសិល្បៈក្នុងផ្លូវល្អវិញ “ ។ តន្ត្រីមិនមែនជាអ្វីដែលអាក្រក់ឡើយ តែជាការបង្ហាញពីអត្តសញ្ញាណរបស់បុគ្គល មិនថាតន្ត្រីដែលគេស្តាប់នោះជាប្រភេទអ្វីឡើយ ម៉្យាង Cambodia DJ Academy ជាសាលាបង្រៀនជំនាញធ្វើយ៉ាងណាឲ្យអ្នកដែលមានបំណងចង់ក្លាយជា DJ ទទួលបានចំណេះដឹងជំនាញដែលគេត្រូវការ យល់ដឹងពីច្បាប់របៀបលាយចម្រៀងចូលគ្នា និងមានជំនឿចិត្តលើខ្លួនឯងហ៊ានបង្ហាញពីសមត្ថភាព និង អាចលេងនិង mix ភ្លេងបានភ្លាមៗដើម្បីតម្រូវតាមចំណង់ចំណូលចិត្តរបស់ទស្សនិកជន។

Cambodia DJ Academy មានគ្រូបង្រៀន DJ ទាំងខ្មែរនិងបរទេស ដែលសុទ្ធតែមានជំនាញពី ១៥ ទៅ ២០ឆ្នាំ ក្នុងក្លឹបនានាក្នុងប្រទេសអាស៊ីអាគ្នេយ៍។ប្រសិនបើមិត្តយុវវ័យមានចំណាប់អារម្មណ៍កុំភ្លេចចូលមើលក្នុងគេហទំព័រ cambodiadjacademy.org និងកុំភ្លេចចូលចិត្តទំព័រ Facebook : Cambodia Dj Academy ៕

Cambodia DJ Academy Director, Mr. Anthony Whyte told Sabay Magz that the course is suitable for everyone – not just for those who wish to be a professionals.The beginner course is great for music lover, and anyone who love to challenge themselves to learn something new. After the 12 hours in the beginner course, students should be able to skillfully mixing, looping, overlapping music on the computer or on the machine as much as a professional. However if students are serious, and want to pick it up as their career, they can continue to Intermediate and Advance classes where there will be more to explore about the art of DJ.

Cambodian people usually lump DJ-ing with clubbing and the wild dangerous night life altogether. However, Director Anthony Whyte said that "The aim of Cambodia DJ Academy is to shift people's perspective on music to a more positive light." Music is not bad, it is a way for people to express themselves. Cambodia DJ Academy is a school that will install professionalism and skills to those who want to be a professional DJ meanwhile also improve the student's confidence to perform on stage, encourage creativity and challenge students to try new music and ability to be flexible in playing music in response to the audience needs.

CambodiaDJ Academy team up with coaches of more than 15-20 years experience in DJ tour in Asia. If you're interested to join the course, don't forget to book it on cambodiadjacademy.org or via facebook : Cambodia Dj Academy.

SMARTPHONE
APPLICATIONS

APP FOR APRIL



APPALERTS

An engine that would definitely keep you ahead of others! It deliver you the latest app coming out and also keyword of the kind of app you prefer. Not to mention the price-drop and the app-gone-free alert! Charming much?

ផ្តល់ដំណឹងពី កម្មវិធីដែលទើបនឹងចេញថ្មីលើ Apple Store និងកម្មវិធីល្អៗផ្សេងៗ ដែលទើបនឹងធ្លាក់ថ្លៃមកជាកម្មវិធី free !



GIF

ជាមួយ gif វិញ អ្នកថែមទាំងអាចតបសារផ្សេងៗ ជាfile gif និងវីដេអូផ្សេងៗ ដែល ជម្រើសទាំងនោះ សុទ្ធ សឹងជារូបនិងវីដេអូរបស់តារាល្បីៗ ហើយមើលទៅកំប្លែងៗ។

Sometimes emoji is just not enough to express yourself ! Spice up your text message and chat with gif and wow your friends with the coolest reply.



GINGER KEYBOARD: BETTER THEME

Personalized your smartphone keyboard but it's actually very functional. Remember the hard moment when you need to rewrite your text many times just so it's formal enough for work? Ginger keyboard correct your little typo and make sure your text professional.

POSTERLABS COLLAGE PHOTO MAKER

Now you can edit photo and make poster like a pro! Posterlabs is an app for beginner designers with easy function tools used to edit photo in high resolution.

VIMO

You had your fun with all the selfie and editing pics, now let's take it to the next like! Vimo allows you to edit videos with kawaii stickers. Homemade video has never been so cute!



HYPERLAPSE

Now you can finally have your picture per- fectphoto!!Hyperlapseisanappthathelp stabilize your camera making your photos or videos comes out smooth with that cine- mic feel even when you're on the move! Say Cheese!!

លក្ខណៈពិសេសរបស់ HONDA MOOVE ល្អដាច់គេទាំងរូបរាង និងបច្ចេកវិទ្យា

HONDA MOOVE ២០១៥ ជាម៉ូតូទំនើបស៊េរីចុងក្រោយបង្អស់របស់ក្រុមហ៊ុន HONDA រចនាឡើងស័ក្តសមបំផុតសម្រាប់យុវវ័យ ទាំងរូបរាង និងបច្ចេកវិទ្យាថ្មីដែលនឹកស្មានមិនដល់។ ម៉ូតូលេខអូតូដែលជាសមាជិកថ្មីរបស់ HONDA នេះមានលក្ខណៈជាច្រើនដូចជា៖ ម៉ាស៊ីន 110cc eSP (Enhanced Smart Power) បំពាក់ដោយបច្ចេកវិទ្យា PGM-FI ប្រព័ន្ធ Idling Stop System ដែលជួយសន្សំសំចៃសាំង LED HEADLIGHT និង ប្រព័ន្ធ Combi Brake System ជាដើម។ពេលនេះអ្នកអាចជ្រើសរើសពណ៌តាមតម្រូវការដូចជា ក្រហម-ស, ស-ខ្មៅ និងទឹកប៊ិច-ស។

LED HEADLIGHT

Honda Moove ត្រូវបានចាត់ទុកជាទោចក្រយានឆ្លាតវៃដំបូងគេក្នុងប្រទេសកម្ពុជាដែលមានការរចនាដ៏ពិសេស និងជម្រើសថ្មីចុងក្រោយដូចជាភ្លើង LED Headlight ជាបច្ចេកវិទ្យា Honda Smart Technology ដែលត្រូវបានបំពាក់ជាលើកដំបូងលើម៉ូតូខ្នាតតូច។ ភ្លើងមុខថ្មី Jet Liner LED 3D ដែលធ្លាប់បានឃើញតែបំពាក់នៅលើរថយន្តប្រណីត តែពេលនេះគឺ **MOOVE** ក៏មានបច្ចេកវិទ្យានេះដែរ។

COMBI BREAK

ជាប្រព័ន្ធដែលភ្ជាប់ហ្វ្រាំងមុខ និងក្រោយចូលគ្នា ពេលចាប់ហ្វ្រាំង សំពាធហ្វ្រាំងនឹងបែងចែកស្មើគ្នាទាំងលើហ្វ្រាំងមុខ និងក្រោយ ធ្វើឲ្យរក្សាលំនឹងបានល្អជាងមុន។

IDLING STOP SYSTEM



ប្រព័ន្ធ Idling Stop System មានអត្ថប្រយោជន៍បំផុតពេលជាប់កកស្ទះចរាចរណ៍យូរ ឬ ពេលបញ្ឈប់ម៉ាស៊ីនតាមភ្លើងសញ្ញាដោយ រាល់ពេលឈប់នៅស្ងៀមម្តងៗ ម៉ាស៊ីនម៉ូតូនឹងត្រូវបញ្ឈប់ដោយស្វ័យប្រវត្តិក្នុងរយៈពេល ៣ វិនាទី ។ អ្នកប្រើប្រាស់គ្រាន់តែមួរ GEAR ទៅមុខ ដោយមិនចាំបាច់បញ្ឆេះម៉ាស៊ីនឡើយ។ពិតជាជួយសន្សំសំចៃប្រេងសាំងបានកាន់តែច្រើន។

ម្ហូបនិងការរៀបចំ
បន្សល់ទុកពីសម័យលង្វែក

ទាវ ជាឈ្មោះ នារីខ្មែរសម័យលង្វែកដែលខ្មែរយើង ផ្សារភ្ជាប់ទៅនឹងភាពស្រស់សោភា អត្តចរិតថ្លៃថ្នូរ គ្រប់លក្ខណ៍របស់ស្ត្រីខ្មែរ ដែលចេះរៀបចំទុកដាក់ផ្ទះសំបែងបានយ៉ាងប្រណិត។ តាមរយៈទស្សនៈរបស់ នេះហើយទើប សណ្ឋាគារ ទាវ ត្រូវបានបង្កើតឡើងក្នុងគោលដៅបង្ហាញភ្ញៀវបរទេសនិងខ្មែរពីការរៀបចំទុកដាក់ បម្រើសេវាកម្មបានល្អមិនឲ្យឃ្មើសចិត្ត។

ទាវ ជាសណ្ឋាគារមានបម្រើសេវាកម្មជាច្រើន តែក្នុងទំព័រនេះ Sabay Magz សូមលើកយកតែផ្នែកភោជនីយដ្ឋានមកបង្ហាញជូន។ ភោជនីយដ្ឋាន TEAV មានបម្រើម្ហូប ខ្មែរ អឺរ៉ុប ក្នុងបរិយាកាសរៀបចំដែលក្លាយចេញពីស្ថាបត្យកម្មបុរាណ ឆ្លងកាត់ការស្រាវជ្រាវផ្សេងៗ លាយជាមួយការប្រើប្រាស់ពណ៌ និងតុបតែងបន្ថែមបែបសម័យធ្វើឲ្យភោជនីយដ្ឋានបង្ហាញនូវ ស្រស់ស្អាតប្លែកពីគេ។

ទាវ មានអាសយដ្ឋានទីតាំងទីមួយស្ថិតនៅ #14ផ្លូវ310 សង្កាត់បឹងកេងកង1 ខណ្ឌចំការមន
និងទីតាំងទីពីរ #30 ផ្លូវ 9 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

ឈុត CINDERELLA
ដាំពេជ្របង្កប់ ១៧០០០០០គ្រាប់
នឹងនាំពាន ACADEMY AWARD ឲ្យអ្នករចនាម៉ូតម្តងទៀតឬអត់？

SANDY POWELL
COSTUME DESIGNER

ឈុតឆាកដែលរំភើបបំផុតនៃរឿង Cinderella គឺស្បែកជើងកែវដែលទស្សនិកជនចាំតាមដានថា Disney នឹងអាចផលិតបានឲ្យបានស្រស់ស្អាតដូចការរំពឹងទុកឬអត់ ប៉ុន្តែក្រោយពីបានឃើញ Poster ហើយ ម្នាក់ៗ ងាកមកនិយាយមិនដាច់ពីមាត់ពីរ៉ូបដ៏ស្រស់ស្អាតរបស់ Cinderella។

Sandy Powell អ្នករចនាម៉ូតឈុតរ៉ូបពណ៌ខៀវដែលបានឃើញក្នុងការផ្សាយពាណិជ្ជកម្មរឿង Cinderella នេះ និយាយថាគាត់ផ្តោតសំខាន់លើភាពឆើតឆាយរបស់ Cinderella ពេលនាងកំពុងរាំ និងឈានជើងរត់ចុះកាំជណ្តើរអឺចឹងហើយទើបគាត់ប្រើសាច់ក្រណាត់ជាច្រើនប្រភេទលាយចូលគ្នាជាង ២៥០ម៉ែត្រ ដើម្បីអោយរ៉ូប Cinderella មើលទៅរស់រវើក ហើយអណ្តែតយឺតៗពេល Cinderella ធ្វើចលនា។ តែអ្វីដែលភ្ញាក់ផ្អើលបំផុតនោះគឺ Powell ដាំត្បូងពេជ្រ ជាង ១០០០០ គ្រាប់បន្ថែមលើរ៉ូបដើម្បីឲ្យរ៉ូប Cinderella រំលេចភ្លឺផ្លេកពេលចាំងពន្លឺភ្លើង។ គ្រាន់ការដាំត្បូងពេជ្រនេះ Powell ចំណាយពេល ៥០០ម៉ោង និងត្រូវការជំនួយពីជាងកាត់ដេរដទៃទៀត ១៨នាក់ទើបធ្វើរួច។

Sandy Powell បង្កើតរ៉ូបម៉ូតតែមួយនេះជា៨ពណ៌ផ្សេងគ្នាដើម្បីប្រាកដចិត្តថារ៉ូបដែលជ្រើសរើសចុងក្រោយនឹងស្អាតដូចការចង់បានរបស់គាត់។ រ៉ូបនីមួយៗ សុទ្ធតែដាំត្បូង ១០០០០គ្រាប់ និងចំណាយកម្លាំងពលកម្មច្រើនដូចគ្នាទាំងអស់ ហើយរួមបញ្ចូលទាំងត្បូងដែល Powellដាំក្នុងឈុតរៀបការរបស់ Cinderella ព្រមទាំងគ្រឿងអលង្ការជាច្រើនឈុតដែលរចនាឡើងឲ្យស៊ីនឹងរ៉ូបគ្រប់ពណ៌នីមួយៗ អ្នករចនាម៉ូតម្ចាស់ពានរង្វាន់ Best Costume Design ៣ លើករូបនេះ ប្រើប្រាស់ ត្បូងពេជ្រសរុប ១៧០០០០០ គ្រាប់។

កាលពីឆ្នាំ ២០១១ Sandy Powell ចាញ់ដៃ Colleen Atwook ម្តងទៅហើយដោយ ឈុតរបស់ Atwood ក្នុងរឿង Alice in Wonderland ឈ្នះឈុតរបស់ Powell ក្នុងខ្សែភាពយន្ត Hugo។ ក្នុងឆ្នាំ ២០១៥នេះខណៈពេលដែល Powell ឈានយកពាន Academy Award អ្នករចនាម៉ូត Atwood កំពុងរចនាម៉ូតឲ្យខ្សែភាពយន្តថ្មី Supergirl ដែលនឹងចេញពេលតំណាលគ្នាដែរ។ តើSandy Powell អាចនឹងសងសឹកដណ្តើមពានពី Atwood បានអត់？

Will Cinderella's 1,700,000 studded diamond dress bring Sandy another Academy Award?

Though the glass slippers are the main spin-off of the Cinderella story, the newly made 2015 Cinderella film most talked about topic is the ball gown designed by Sandy Powell.

Sandy Powell is known for her master pieces in designing historical style dresses of the 19th centuries that brought her 3 academic awards from "Shakespeare in Love" "The Aviator" and "The Young Victoria." This year round she's stirring fashion enthusiastic fans once more with the classic design of the Cinderella dress with a twist.

Powell said that the dressed is envisioned to be a true magic when Cinderella dances and running down the stair. The dress should have a life of its own and float around her. In order to accomplished that, Powell used as much as 250 meters combination of silk, polyesters, chiffon to make 7 layer dress that audience can clearly see the large thick hem as Cinderella twirl in the ballroom. To reflect the light and make the dress give-off that fairy godmother magical glitter, Powell even have 18 tailors to hand print all 10,000 Swarovski diamonds to the dress. The process took at least 500 hours to complete.

To get that perfect dress, Powell even make 8 different version of Cinderella dresses – each embodied with 10,000 diamonds and each took the same amount of labor and hard work. The only distinction is the color, as Powell wanted to stray from the cliche blue dress and she decided to try other colors including silver, green and lilac but then decided to go back to blue. All 8 Cinderella dresses combined with several versions of Cinderella wedding dress and each jewelry set to goes with each costume design resulted in the use of at least 1,700,000 Swarovski diamonds.

Last time Powell was nominated for the Academy Award but miss the chance as Colleen Atwood grab the trophy for her costume design in Alice in Wonderland (2011). And now they're coming head to head once again as Atwood is designing Supergirl outfit to be competed for the Academy Award too. Will Cinderella bring enough magic to win her 4th Best Costume Designer?

រត់បះសក់ SIR, YES SIR!
03 APRIL 2015

ក្នុងក្លឹបបណ្ដុះបណ្ដាលទាហានមួយមានកូនទាហាន២ក្រុមដែលឈ្លោះគ្នាកាច់កុងគ្នាមិនចេះចប់និយាទៅគឺមិនដែលត្រូវគ្នាតាំងពីរៀននៅវិទ្យាល័យជាមួយគ្នាម្ល៉េះ។ តែក្រៅពីសង្គ្រាមក្នុងក្រុម មានរឿងមួយដែលគេសង្កេតឃើញជាប្រចាំមានហេតុការណ៍ចម្លែកកើតឡើងរហូតក្នុងបន្ទាយនៅពេលយប់ហើយមិនយូរប៉ុន្មានគេរកឃើញការពិតថាមេបញ្ជាការ Danai ជាខ្មោច! ក្រុមទាហានទាំង២ក្រុមបង្ខំចិត្តធ្វើយ៉ាងណាឲ្យត្រូវគ្នាវិញមិនអីចឹងទទួលពិន័យទៅហាត់បន្ថែមជាមួយមេបញ្ជាការ Danai ទៀតហើយ!

In a 3rd year military course at Khao Chon Kai, two groups of military students are trying to dominate each other. The conflicts and bullies started since they were in high schools. Other than the conflicts between the two gangs, there seems to be a mystery along their military course here, especially at night time. Not so long, they have found out that one of their current mentor, sarge Danai, was dead. They need to bare on an extra field practice from the sarge.

KUBOT
17 APRIL 2015

Makoy ធ្វើដំណើរមកទីក្រុងម៉ានីឡាវិញក្រោយពីជួបឧប្បត្តិហេតុដែលតម្រូវឲ្យគាត់ប្រយុទ្ធជាមួយពួកបិសាច Aswang ដែលជាបិសាចស៊ីមនុស្ស។ ពេលមកដល់ទីក្រុងវិញគាត់សង្ឃឹមថានឹងបានរស់នៅដោយសុខសាន្តជាមួយសង្សារហើយតែអ្វីដែលគាត់មិនដឹងគឺពួក Aswang មួយហ្វូងបានលបតាមដាន Makoy មកដល់ទីក្រុងដែរ។ ក្រៅពីសងសឹកដែល Makoy បានសម្លាប់គ្នាវាអស់ច្រើនអ្នកវាមកនេះចង់សម្លាប់ស៊ីសាច់មនុស្សគ្រប់គ្នាតែម្ដង ប្រកាសសង្គ្រាមរវាង មនុស្សនិង Aswang ។

Makoy traveled from to Manila thinking that he's now far away from the blood-crusted ground of Pulupandan. Thinking that the worst is over and finally he can settle down with his lover, little did he know he was tailed by a herd of blood thirsty Aswang who will stop at nothing to bring down the man that kill so many of their own – and probably have a killing rampage along the way. The worst is not over – it is yet to begin.

SINGLE LADY
23 APRIL 2015

Bright ជា Idol ក្នុងចិត្តនារីៗខ្លួនមួយគ្រប់គ្នាតែម្ដង! នាងជឿជាក់ថាថាមិនចាំបាច់ត្រូវការមានស្នេហាស្រីៗក៏អាចរស់នៅបានដោយសប្បាយចិត្តនិងជោគជ័យក្នុងជីវិតដែរ។ ថៃដន្យអាក្រក់នោះត្រង់នាងត្រូវគ្រូទាយបានទាយថានាងត្រូវការស្នេហាបើមិនអីចឹងនឹងសយមួយជីវិតហើយ! ដំបូង Bright មិនជឿទេតែក្រោយពីត្រូវបញ្ឈប់ពីការងារនាងចាប់ផ្ដើមគិតមើលហើយថាសង្សារមួយណានាងត្រូវទៅរកដើម្បីឲ្យជីវិតនាងបានសុខសាន្តម្ដងទៀត។ អាចឬអត់ដែលស្នេហាដែល Bright កំពុងស្វែងជាបុរសម្នាក់ដែលនៅក្បែរនាងតាំងពីដើមតែនាងមិនបានយកចិត្តទុកដាក់?

Bright is the ultimate icon of single women– a strong independent author and media face of a woman who live a happy and successful life even without a lover. However, the media darling was told by a fortune teller that her life will turn for the worst because she still have unresolved love business and after that she got suspended from work! Now she just need to figure out which one of the unresolved love she need to deal with so she can some peace back in her life – is it one of her ex or the new guy who stick with her all these times?

MONSTERS : DARK CONTINENT
24 APRIL 2015

ក្រោយពីសង្គ្រាមជាមួយពួក Monster ជាង10ឆ្នាំមក ពួក Monster កាន់តែពង្រីកទឹកដី កាន់កាប់របស់ខ្លួន (Infected Zone) ហើយរដ្ឋាភិបាលត្រូវបង្ខំចិត្តបន្ថែមទាហានកាន់តែច្រើនទៅប្រយុទ្ធមុនពេល Infected Zone រីករាលដាល។ ទាហាន4នាក់ដែលទើបនឹងចាត់តាំងចូលជួរកងទ័ពមិនរអានឹងប្រយុទ្ធជាមួយពួកបិសាច Monster ឡើយ។ ក្រោយពីគេទទួលបាន បេសកកម្មពិសេសទៅ រំដោះ ទាហាន 5រូបក្នុងតំបន់របស់ Monster ហើយត្រូវឈានជើងចូលសម្បុករបស់ពួកបិសាច Monster ទើបពួកគេដឹងថាស្ថានការពិតអាក្រក់ប៉ុណ្ណា ពេលត្រូវឈរមើលពួកMonster បំផ្លាញភពផែនដីនៅនឹងភ្នែក។

Monsters : Dark Continent
A team of 4 new recruits from Detroit are really excited to finally put their skill into action – They are now the soldiers to help fight in the alien war that has been going on for 10 years! The Monsters are expanding their territory and now reaching Middle East but the Detroit newbies are not afraid; they merely treat this war as a game to conquer the odds like some sci-fi movie. That is until they receive a mission to rescue 5 soldiers from the Infected Zone and have to stand and watch the destruction of their planet in front of their very eyes.

PLATINUM cineplex
ផ្លាទីណៀម សូរិយា ជាន់ទី5
BOOKING » 081/086-666-210
Google play
App Store
INTERNATIONAL DIGITAL 3D CINEMA
WWW.PLATINUMCINEPLEX.COM.KH

RUN ALL NIGHT 03 APRIL 2015

កំពូលឃាតក Jimmy Conlon ត្រូវជ្រើសរើសរវាងកូនប្រុសខ្លួនឯង MikE និងសំឡាញ់ Shawn ដែលស្គាល់គ្នាជាងមួយជីវិតហើយ។ Jimmy ដឹងថាមិត្តរបស់គាត់ចង់សងសឹកព្រោះ Mike បានសម្លាប់កូនរបស់ Shawn តែក្នុងសង្គមងងឹតដែលពួកគេរស់នៅ មនុស្សសម្លាប់គ្នាមិនចេះចប់ Shawn និងកូនរបស់គាត់ក៏សម្លាប់មនុស្សមិនចេះតិចមិនមែនជាមនុស្សស្លូតត្រង់អ្វីផង។ ប៉ុន្តែសង្គមងងឹតមានច្បាប់របស់សង្គមងងឹតហើយមិនមាននរណាបំពានច្បាប់នោះហើយរត់គេចបានយ៉ាងងាយៗនោះឡើយ។

The infamous hit-man Jimmy Conlon has to make a choice – saving his son, Mike, or go against his lifetime best friend, Shawn Maguire. Jimmy knows his son killed Shawn Maguire's son but that was a mistake and it's not like Shawn and his son are some innocent white collar people, they killed people for money themselves! However, the underworld, has a rule of its own. And no crimes go unpunished.

DISTRIBUTED BY

sabay/mvp

រូបភាពក្រៅឆាកនៃរឿង រត់បះសក់

SUNDAY

1122887	សេរីមន្ត និង ស្រីពៅ	ចូលឆ្នាំសង្ឃឹមបានរាំនឹងអូន	Sunday Vol191
1122888	សេរីមន្ត និង ស្រីពៅ	ចូលឆ្នាំទៅលេងអង្គរ	Sunday Vol191
1122889	សេរីមន្ត	រាំកាឡុក	Sunday Vol191
1122890	ស្រីពៅ	រាំនឹងខ្ញុំ	Sunday Vol191
1122891	មុនី និង ស្រីនាង	ក្រមុំចាស់ប៉ះកំលោះភ្នែកអារ	Sunday Vol191
1122892	សេរីមន្ត	សាច់អាំងឈ្ងុយពេកទើបចង់ផឹក	Sunday Vol191
1122893	អ៊ីណូ និង តាក់ម៉ា	ត្រូវម៉ាដុំដី	Sunday Vol191
1122894	អ៊ីណូ	នាងស៊ីមពីរសោះ	Sunday Vol191
1122895	សេរីមន្ត	ខូចចិត្តហើយ	Sunday Vol191
1122896	សេរីមន្ត	បេះដូងឱកដាក់	Sunday Vol191
1122897	តាក់ម៉ា	ក្រមុំកើតអ៊ុតស្វាយ	Sunday Vol191
1122898	ខាន់ ជេម៍	បិសស័យប៉ះប្រពន្ធគេ	Sunday Vol192
1122899	សុខ ពិសី	ស្រីស្អាតតែប៉ុណ្ណឹង	Sunday Vol192
1122900	ជេម៍ និង ក្រូច និង ជើម	បើអីចឹងមែននោះ	Sunday Vol192
1122901	នីកូ និង ពិសី	ប្រពន្ធខ្ញុំក្រមុំមិនដូរ	Sunday Vol192
1122902	ក្រូច	អស់អាលីងហ្វង	Sunday Vol192
1122903	អ៊ីត និង ជើម	ប៉ក់ក្លាំង	Sunday Vol192
1122904	បូទី	ពួកម៉ាកខ្ញុំសង្សារទាត់ចោល	Sunday Vol192
1122905	នីកូ	ស្នេហារល់រល់	Sunday Vol192
1122906	សុខ ពិសី	មុនញ៉ុំខ្ញុំកក់ពេទ្យទុកផង	Sunday Vol192
1122907	សុខ ពិសី	ម៉ែអើយចេកសោះ	Sunday Vol192
1122908	ខាន់ ជេម៍	នារីខ្មែរ	Sunday Vol192
1122909	ឆាយ វីរៈយុទ្ធ	អូនមកពីវត្តណា?	Sunday Vol193
1122910	សាលី និង អ៊ីត	ប្រពន្ធខ្ញុំឡើងដំណែងថ្មី	Sunday Vol193
1122911	វីរៈយុទ្ធ និង សុវណ្ណារី	ចាំបងក្លាយជាសេដ្ឋី	Sunday Vol193
1122912	ប៊ុន សក្តិ	ក្រមុំខ្មែរល្អមែន	Sunday Vol193
1122913	លីនដា	នឹកស្រុកនឹកស្រែ	Sunday Vol193
1122914	មាស សាលី	ស្រវឹងរាប់ញាតិ	Sunday Vol193
1122915	ឆាយ វីរៈយុទ្ធ	បានធ្វើការរោងចក្រអូនភ្លេចស្រែ	Sunday Vol193
1122916	វីរៈយុទ្ធ និង សុវណ្ណារី	លង់ស្នេហ៍ក្រមុំកងមាស	Sunday Vol193
1122917	ឆាយ វីរៈយុទ្ធ	មន្តស្នេហ៍ម៉ាឌីហ្សុន	Sunday Vol193
1122918	ឆាយ វីរៈយុទ្ធ	ឆ្នាំថ្មីឱ្យបងរាំជាមួយអ្នកណា?	Sunday Vol193
1122919	ឆាយ សុវណ្ណារី	ប្រុសខ្មែរគួរឱ្យស្រលាញ់	Sunday Vol193

KlapYaHandz

BEELINE	SMART	CELLCARD	METFONE		
900376	309981	709749	1122550	Ago	ទោះជាបងដឹង
900377	309982	709750	1122551	Theny ft Gang	ប្រលងរាំសារ៉ាវ៉ាន់
900378	309983	709751	1122552	SreyLeak ft Prof Kinski	ពេលលើមស្រិចៗ
900379	309996	709752	1122553	Ago	លាហើយប៉ារីស
900380	305002	709753	1122554	Theny	អូនដើរកាត់ព្រៃ
900381	305003	709754	1122555	Sreyleak	ស្នេហ៍ក្នុងពេលរាត្រី
900382	305004	709755	1122556	Ago	អក្ខាដែលបងសរសេរទៅ
900383	305005	709756	1122557	Sreyleak ft Lisha	កាលខ្ញុំនៅពីក្រមុំ
900384	305006	709757	1122558	Ago	ពោះមាយហ៊ុហា
900385	305007	709758	1122559	Sreyleak ft paplar	សារ៉ាវ៉ាន់ស្លឹកខ្យល់
900386	305008	709759	1122560	Sreyleak ft Gobshite	សារ៉ាវ៉ាន់រកគូ
900387	305009	709760	1122561	Ago	អនុស្សាវរីយ៍សមុទ្រព្រាត់

HEAR MY SONG

BEELINE	CELLCARD	METFONE		
900389	711728	1122738	ខាំចេន	សង្សារបីថ្ងៃ
900390	711729	1122739	ចិត្ត កញ្ញានា	ភ្លេចខ្លួន
900391	711730	1122740	ឈូកសុខា	Don't Cry
900392	711731	1122741	យឹង យន	សម្រស់Florida
900393	711732	1122742	រុន ស៊ីហ៉ា	ច្រណែនគេដែរមិនមែនជាខ្ញុំ
900394	711733	1122743	Leav david	Tiamo
900395	711734	1122744	Sang Sok Serey	ពន្លឺ
900396	711735	1122745	សេង សុវណ្ណដារ៉ា	ទឹកភ្នែកពណ៌ភ្លៀង
900397	711736	1122746	ឡាលីន	យុវជន និងការងារសហគមន៍
900398	711737	1122747	អូនបថម	ស្នេហាស្មោះសរ

sabay music

METFONE	CELLCARD	SMART	BEELINE
SMS: SET [SONG CODE] send to 1772	SMS: [SONG CODE] send to 2727	SMS: [SONG CODE] send to 855	SMS: [SONG CODE] send to 1221

យ៉ង ពៅ ៖ « បើស្រលាញ់សិល្បៈតន្ត្រីសូមស្រលាញ់ឲ្យអស់ពីបេះដូង »

គ្មានអ្នកណាម្នាក់ធ្វើការដោយមិនគិតពីរឿងក្រពះនោះទេ ហើយបើនិយាយពីក្នុងវិស័យសិល្បៈតន្ត្រីវិញ បើរវល់តែគិតពីរឿងក្រពះពេក សិល្បៈខ្មែរនឹងមិនរីកចម្រើនទៅមុខទេ។ នេះជាការលើកឡើងរបស់ លោក យ៉ង ពៅ Music Producer និងចាងហ្វាងស្ទូឌីយោ ដែលបទពិសោធន៍លើផ្នែកតន្ត្រីជាង ២០ ឆ្នាំ។

សំដៅលើការផលិតបទចម្រៀងថ្មីដែលកំពុងចរាចរណ៍លើទីផ្សារបច្ចុប្បន្ននេះ លោក យ៉ង ពៅ ប្រាប់ទស្សនាវដ្ដី Sabay បន្តទៀតថា សិល្បៈតន្ត្រី និងចម្រៀងប្រទេសសព្វថ្ងៃនេះកំពុងឈានទៅមុខហើយ ព្រោះលោកសង្កេតឃើញថាយុវវ័យឥឡូវនេះ មានគំនិតច្នៃប្រឌិត និងបង្កើតបទភ្លេងថ្មីច្រើនណាស់ តែក្នុងនោះអ្នកដែលអង្គុយចាំតែចម្លងពីបរទេសក៏មានច្រើនដែរ និយាយរួមគឺធ្វើការមិនអស់ពីចិត្ត ប្រហែលជាមកពីគិតតែរឿងលុយក្នុងហោប៉ៅពេក។

« ដូច្នេះបើយើងស្រលាញ់សិល្បៈផ្នែកនេះអស់ពីបេះដូង ហើយធ្វើចេញពីចិត្តអស់ពីពោះ ខ្ញុំជឿថាសិល្បៈយើងនឹងរីកចម្រើន »។ លោក យ៉ង ពៅ និយាយទាំងមានជំនឿក្នុងចិត្ត។

លោក បន្ថែមថា ហ៊ាននិយាយបែបនេះ ដោយសារលោកមានទំនាក់ទំនងជាមួយសិល្បៈករផ្នែកតន្ត្រី និងអ្នកនិពន្ធជើងចាស់សល់ពីសម័យមុន ដែលតែងតែផ្ដល់ដំបូន្មានល្អៗដល់សិល្បៈករជំនាន់ក្រោយដូចជារូបលោក។ តាមរយៈស្នាដៃផលិតបទចម្រៀងផ្សេងៗ ដែលសិល្បករខ្មែរជំនាន់មុនបានបង្កើត គិតមកទល់ពេលនេះបទរបស់ពួកគាត់នៅតែទទួលបានបានគាំទ្រជានិច្ចក្នុងបេះដូងខ្មែរ។

ហេតុអ្វីបានជាបទចម្រៀងសម័យដើមមាននៅតែល្បីដល់សព្វថ្ងៃ?

សិល្បករផ្នែកតន្ត្រីដែលមានបទពិសោធន៍ជាង ២០ ឆ្នាំមកនេះ បកស្រាយទាំងទឹកមុខញញឹមថា៖ « ដូចខ្ញុំនិយាយដដែលៗចឹង បើយើងធ្វើអីមួយអស់ពីបេះដូង ហើយយកសិល្បៈជាធំនោះ លទ្ធផលប្រាកដមិនអាចកាត់ថ្លៃបានឡើយ ព្រោះគេធ្វើដើម្បីសិល្បៈខ្មែរ»។

រៀមច្បងសិល្បៈជំនាន់មុនបានប្រាប់លោកថា ពេលដែលនិពន្ធបទចម្រៀងណាមួយ អ្នកនិពន្ធ និងអ្នកភ្លេងគឺដូចជាមនុស្សតែមួយ និយាយរួមគឺចំណាយពេលដាក់អារម្មណ៍លើការងារនេះច្រើនណាស់។

លោក ពៅ រំឭកបន្តទៀតថា៖ « តាមបទពិសោធន៍មួយនេះ យើងអាចសិក្សារបានថាពាក្យថាភ្លេងមួយម៉ាត់មិនមែនចេះតែធ្វើលេងៗនោះទេ គ្រប់ដំណាក់កាលនៃការនិពន្ធគឺសុទ្ធតែប្រើបេះដូង និងអារម្មណ៍ទាំងអស់ ដូច្នេះក្នុងនាមអ្នកស្រលាញ់សិល្បៈផ្នែកនេះ ខ្ញុំសូមលើកទឹកចិត្តដល់យុវវ័យទាំងអស់សូមស្រលាញ់សិល្បៈចម្រៀងខ្មែរយើង ឲ្យអស់ពីបេះដូងហើយកុំគិតរឿងលុយកាក់ជាធំពេក »។

លោក យ៉ង ពៅ ចាប់ផ្ដើមរៀនភ្លេងតាំងពីអាយុ ៨ ឆ្នាំ គិតមកទល់ពេលនេះ លោកបានធ្វើការជាមួយសិល្បៈជាង ២០ ឆ្នាំហើយ ក្នុងនោះលោកបាននិពន្ធបទចម្រៀង និងរៀបចំបទភ្លេងដល់សិល្បករដែលបង្កើតបទចម្រៀង Original ជាច្រើនបទមកហើយ។ បច្ចុប្បន្ននេះលោកមានបន្ទប់ស្ទូដីយោផ្ទាល់ខ្លួនមួយ ដែលផ្ដល់សេវាកម្មផលិតបទចម្រៀង សរសេរទំនុកច្រៀង និងកែសម្រួលបទភ្លេង។ ស្ថិតក្រោមស្ទូដីយោឈ្មោះ Bosba media លោកទទួលស្វាគមន៍ជានិច្ចដល់យុវវ័យទាំងឡាយណា ដែលចូលចិត្តនិពន្ធបទចម្រៀង Original ហើយត្រូវការអ្នកជួយផ្គត់ផ្គង់ក្នុងការផលិត៕

សង្ខេបរឿង ស្លឹកចាក

ស្លឹកចាកជាខ្សែរឿងដែលឆ្លុះបញ្ចាំងពីកម្រងជីវិតរបស់យុវតីម្នាក់ ដែលរស់នៅក្នុងស្រុកទឹកវិល ក្នុងខេត្តកំពត ក្នុងគ្រួសារក្រីក្រតោកយាកជាមួយម្ដាយ និងឪពុកដែលមានវ័យ២៧ឆ្នាំ និង៣០ឆ្នាំ។ ឪពុករបស់នាងបានចាកចេញទៅប្រទេសថៃដើម្បីស្វែងរកការងារនៅពេលដែលនាងមានវ័យត្រឹមតែ៤ឆ្នាំ។ បន្ទាប់ពីនាងចាកចេញទៅ នាងត្រូវរស់នៅជាមួយម្ដាយ ជាមួយប្អូនប្រុសម្នាក់។ ម្ដាយរបស់ចាកឈ្មោះនន ត្រូវបំពេញកតប្បកិច្ចជាម្ដាយ និងជាឪពុកដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរអោយបានរៀនសូត្រ។ ក្នុងសុបិន្តរបស់ចាកគឺចង់ត្រឹមតែក្លាយជាគ្រូពេទ្យម្នាក់ក្នុងភូមិដើម្បីជួយព្យាបាលអ្នកទីទាល់ក្រ។

ននដែលជាម្ដាយត្រូវធ្វើការងារគ្រប់បែបយ៉ាងដើម្បីទប់ទល់និងជីវភាព ជាកម្មករសំណង់ផង និងលក់នំចាកនៅទឹកឈូង។ របរលក់នំចាកមិនបានគាប់ប្រសើដូចឆ្នាំមុន ឡើយ។ អ្នកទីក្រុងមិនបានចាប់ងារម្មណ៍នឹងជារនំចាកដូចមុនទៀតឡើយ។ ទាំងយាយរបស់ចាក និងម្ដាយរបស់ចាកបានឈប់ធ្វើនំចាកលក់ដូចមុនទៀតហើយ។ ននបានសូមកូនស្រីរបស់ខ្លួន (ចាក)ដើម្បីមករកការងារធ្វើនៅភ្នំពេញ។ ចាកព្យាយាមសុំម្ដាយដើម្បីឈប់រៀន និងបានជួយរកស៊ីម្ដាយ នាងបានពោលពាក្យថា (នាងអាចលក់កែវភ្នែកទាំងគូររបស់នាងជាថ្នូរនឹងប្រាក់ ដើម្បីជួយម្ដាយ និងអាចរស់នៅក្បែរម្ដាយ)។

ននបានមកបំពេញការងារជាបុគ្គលិកអនាម័យក្នុងភោជនីយដ្ឋានមួយក្នុងទីក្រុង ភ្នំពេញ។ ទីនោះហើយដែលជីវិតរបស់ននត្រូវបញ្ចប់ដោយជម្ងឺប្រចាំកាយរបស់នាង។
ចាកត្រូវបានក្រុមគ្រួសារម្ចាស់ភោជនីយដ្ឋានយកមកចិញ្ចឹមបីបាច់ថែរក្សា រៀន សូត្រ។ ៨ឆ្នាំកន្លងផុតទៅ។ ចាកបានចូលរៀនក្នុងមហាវិទ្យាល័យមួយ។ ចាកមានសេចក្ដីសង្ឃឹម និងខំប្រឹងសិក្សារៀនសូត្រ។ តែជីវិតរបស់នាងមិនបានគាប់ប្រសើរទេ នាងបានរត់ចេញពីផ្ទះដែលនាងតែងធ្លាប់គិតថាជាជំរកដ៏សុខសាន្ត។

ចាកត្រូវបានបងចិញ្ចឹម ឈ្មោះ ណាតចាប់រំលោភរហូតមានផ្ទៃពោះ។ ចាកមិនអាចបន្តនៅផ្ទះនោះបាន ព្រោះមិនចង់អោយគ្រួសារល្អក់កករដោយសារនាង។និងម៉្យាងណាតត្រូវចេញទៅសិក្សានៅក្រៅប្រទេសផង។ ណាតបានព្យាយាមដើម្បីស្វែងរកចាក និងសុំចាករួមរស់ជាប្ដីប្រពន្ធ តែចាកបានសំរេចចិត្តថានាងមិនអាចទទួលយកបាននិងឆ្លើយតបទៅណាតវិញថា រឿងរ៉ាវដែលបានកើតកន្លង ចាត់ទុកថាជាការតបស្នងសងគុណចំពោះក្រុមគ្រួសាររបស់ណាតដែលបានចិញ្ចឹមអោយនាងបានរៀនសូត្រ។



ជីវិតរបស់ចាកបានរសាត់អន្ដែត ប្រៀបបីដូចជាស្លឹកចក រសាត់តាមទឹកហូរ។ ចាកប្រសូត្របានកូនស្រីម្នាក់ មានការងារជាស្ត្រីបំរើការងារតាមរងសាល។ និងមិនអាចត្រឡប់ទៅស្រុកកំណើតរបស់នាងវិញក្នុងសភាពបែបនេះទេ។

ប្រាំឆ្នាំកន្លងផុតទៅបានវិលត្រឡប់ពីរៀននៅបរទេសវិញ និងបន្តតាមរកចាកដូចដែលបានសន្យា។ ជីវិតជួបជុំជាប្ដីប្រពន្ធមិនបានប៉ុន្មានផង ណាតត្រូវបានបាញ់សម្លាប់ និងចាកត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើប្លន់គ្រឿងអល្ល័ង្ការរបស់ភ្ញៀវក្នុងបន្ទប់ការ៉ាអូខេ។
នៅក្នុងមន្ទីឃុំឃាំងចាកប្រសូត្របានកូនប្រុសម្នាក់ដែលមុខមាត់ដូចណាត។ ចាករស់ក្នុងមន្ទីឃុំឃាំងបានជិតមួយឆ្នាំដើម្បីរងចាំបណ្ដឹងសាលាឧទ្ធរណ៏។ ទីនោះហើយដែលចាកបានជួបជុំ និងរស់នៅជាមួយបងស្រីជាអ្នកទោសដូចគ្នា។
បន្ទាប់ពីចេញពីមន្ទីឃុំឃាំងចាកបានវិលត្រឡប់ទៅស្រុកកំណើត។ ចំណែកសុខាដែលជាមិត្តដល់ជិតស្និតរបស់ចាកតាំងពីកុមារភាពក៏បានវិលត្រឡប់ពីសហរដ្ឋមេរីក វិញ និងបានចូលស្ដីដណ្ដឹងចាកដោយមិនបានគិតថា ចាកមានកូនឥតខាន់ស្លា ឬមានប្រវិត្តជាស្រីបំរើតាមរងសាលទេ។

ចាកបានបំពេញក្ដីស្រម៉ៃរបស់ខ្លួន គឺនាងបានបញ្ចប់ការសិក្សាផ្នែកថែរទាំសុខភាពសាធារណ និងបានក្លាយជាគ្រូពេទ្យនៅមណ្ឌលសុខភាព ស្រុកទឹកវិល។ ខ្សែភាពយន្តនេះ នឹងចាក់បញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ MyTV នៅថ្ងៃទី ២៧ ខែមេសា។

****ចប់ដោយសង្ខេប****

ថៃសាន

និយាយពីស្នាដៃសិល្បៈគំនូរ មិនអាចកាត់ថ្លៃបាននៅកម្ពុជា

សិល្បៈគំនូរ ជាសិល្បៈមួយដែលអាចនិយាយបានថា មានយុវវ័យភាគតិចណាស់ ជ្រើសផ្នែកនេះ ព្រោះការងារនេះត្រូវប្រើពេលវេលា និងគំនិតស្រមើស្រមៃច្រើនក្នុងការគូសវាសរូបផ្សេងៗដូចជានៅលើក្របសៀវភៅប្រលោមលោកជាដើម។ ក្រៅពីអត្ថន័យនៃសៀវភៅ រូបភាពក្របមុខ និងរូបក្នុងសៀវភៅជាចំណុចសំខាន់មួយដែរ ដែលទាក់ទាញអ្នកអានឲ្យយកសៀវភៅមួយក្បាលមកអាន។ ក្នុងទំព័រនេះ Sabay Magz សូមណែនាំឲ្យស្គាល់វិចិត្រករ ដែលបានបង្ហាញស្នាដៃរបស់លោកលើសៀវភៅប្រលោមលោកខ្មែរ និង និទានកុមារផ្សេងៗរាប់រយក្បាល គឺ លោក ថៃ សាន។

“សិល្បៈមានតម្លៃធំធេងណាស់មិនអាចវាស់ដោយទឹកប្រាក់បានឡើយ” នេះជាសំដីរបស់លោកថៃសានដែលជាវិចិត្រករគូរគំនូរផ្ទាល់ គាត់បាននិយាយពន្យល់បន្ថែមលើឃ្លានេះថាការងារសិល្បៈគឺគេផ្តល់តម្លៃលើគុណភាព មិនមែនតម្លៃគិតជាទឹកប្រាក់ឡើយ។ ការងារដែលគេផ្តល់ឲ្យមិនថាគេជួលយើងក្នុងតម្លៃណាមួយឡើយ ឧបមាបើគេឲ្យត្រឹម១សន្លឹក$៥ក៏ដោយចុះ ក្នុងនាមយើងជាអ្នកគំនូរត្រូវផ្ចិតផ្ចង់ឲ្យអស់ពីសមត្ថភាព ព្រោះនោះជាការងារ និង ទំនួលខុសត្រូវ របស់យើង ហើយស្នាដៃសមិទ្ធផលចុងក្រោយ ផ្ទាំងគំនូរដែលគូររួចនោះជាស្នាដៃរបស់យើងផ្ទាល់តែម្តង។

ស្នាដៃរបស់អ្នកសិល្បៈម្នាក់ៗបញ្ជាក់យ៉ាងច្រើនពីអត្តសញ្ញាណរបស់គេ។ ស្នាដៃគំនូរដែល វិចិត្រករថៃសានគូរឡើងភាគច្រើនជាផ្ទាំងគំនូររូបមនុស្ស (Portrait) ពិសេសគឺរូបនារីសម័យបុរាណដែលក្នុងនោះមានរំលេចយ៉ាងលំអិតលើក្បាច់គ្រឿងអលង្ការដែលពាក់ ព្រោះលោក ថៃ សាន ចង់រក្សាក្បាច់ខ្មែរឲ្យគង់វង្សយូរអង្វែង។

ការងារសិល្បៈគូរគំនូរ ជាការងារបែបច្នៃប្រឌិតមួយដែរដែល តម្រូវឲ្យសិល្បករត្រូវមានគំនិតថ្មីៗ ចេះមានការចង់ចេះចង់ដឹងរៀនជំនាញថ្មីៗ ជានិច្ច។ ចំពោះលោកថៃសាន ផ្ទាល់ការគូរគំនូរលើកុំព្យូទ័រនេះផ្ទាល់មិនមែនជាអ្វីដែលគាត់បានសិក្សាក្នុងឧត្តមសិក្សាសាកលវិទ្យាល័យ វិចិត្រ សិល្បៈឡើយ។ ដំបូងបំផុតវិចិត្រករគំនូររូបនេះ សិក្សាគូរគំនូរលើផ្ទាំងក្រណាត់ដោយប្រើប្រេងប៉ុណ្ណោះ ប៉ុន្តែចំណង់ចំណូលចិត្តលើផ្នែកគំនូរនេះ ជំរុញឲ្យសិល្បៈករវ័យ៣៤ឆ្នាំរូបនេះចេះបែបគំនិតទៅសិក្សាបន្ថែមជំនាញផ្សេងៗដូចជា ការគូរគំនូរលើកុំព្យូទ័រ ជាដើម ទើបជាប់ជាអាជីពមកដល់សព្វថ្ងៃ។ លោក ថៃសាន បានប្រាប់ Sabay Magz ថាក្រៅពីជំនាញគូរគំនូរលើក្រកសៀវភៅនេះដោយប្រើកុំព្យូទ័រនេះ គាត់ក៏បានទៅសិក្សានៅប្រទេសថៃ ដើម្បីបានជំនាញ ថ្មីមួយទៀតគឺ ការគូររូបលើកញ្ចក់ដែលនៅប្រទេសកម្ពុជាមិនទាន់មាននៅឡើយតាមការសង្កេតរបស់លោក។ “ ប្រសិនបើមានពេលវេលានិងថវិកាគ្រប់គ្រាន់ ខ្ញុំនឹងសិក្សាបន្ថែមជំនាញគូរគំនូរជាលក្ខណៈ 3D ទៀត! “ លោកថៃសាននិយាយបន្ថែម។

ថៃ សាន វិចិត្រករខ្មែរ ដ៏ប៉ិនប្រសប់មួយរូប មានស្នាដៃជាច្រើនលើក្របសៀវភៅប្រលោមលោក និងដាក់បង្ហាញស្នាដៃផ្សេងៗតាមព្រឹត្តិការណ៍ជាតិសំខាន់ៗ។ បច្ចុប្បន្ននេះ លោក ថៃ សាន កំពុងធ្វើការនៅអង្គការគ្រួសារថ្មី មានតំណែងជាគណកម្មកាសញ្ញា គូរសញ្ញាគថ្លង់៕

មានអ្វីខ្លះនឹងកើតឡើងនៅ Kids City ក្នុងខែនេះ?

ថ្ងៃទី ០៥ ខែមេសាឆ្នាំ២០១៥

HAPPY EASTER DAY!

Kids City ចែក cookies សម្រាប់អតិថិជនទិញសំបុត្រ និង មានចែកពងមាន់ដល់ក្មេងៗទាំងអស់ដោយឥតគិតថ្លៃ! នំ Cookie ដែលបានមកអាចយកទៅ decorate ដោយប្រើ icing រចនាជាម៉ូតផ្សេងៗ។ តែអ្វីដែលមិនអាចរំលងបាននៅថ្ងៃ Easter Day គឺ Egg Hunting!!ស្វែងរកពងមាន់ដែលលាក់ទុកនៅ ជាន់ playground និង clip&climb រួចយកមករចនាជា Easter Egg ដែលមានម៉ូត cute! ជាងនេះទៅទៀត សាលាអន្តរជាតិ Zaman ក៏បានរៀបចំទស្សនកិច្ចសិក្សាមក Kids City ដើម្បីចូលរួមលេងកម្សាន្តថ្ងៃបុណ្យ Easter ដ៏សប្បាយរីករាយនេះផងដែរ។

ថ្ងៃទី១៤ ដល់ ថ្ងៃទី ១៦ខែមេសាឆ្នាំ២០១៥

អបអរសាទរបុណ្យចូលឆ្នាំខ្មែរ!

ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរKids City មានកម្មវិធីចែកជូនកាដូពិសេសដល់អតិថិជនទាំងអស់ដែលកើតឆ្នាំពពែហើយកាដូដ៏ពិសេសនោះគឺFree Pass សម្រាប់ការចូលលេងកម្សាន្តដោយឥតគិតថ្លៃ។Kids City មានកម្មវិធីពិសេសៗជាបន្តបន្ទាប់សម្រាប់ការចូលរួមអបអរពិធីបុណ្យចូលឆ្នាំថ្មីរយៈពេល៣ថ្ងៃដោយផ្តល់ជូនអតិថិជននូវភាពសប្បាយរីករាយមានដូចជាការសម្តែងនិងបង្ហាត់របាំប្រពៃណីខ្មែរ និង ការលេងកម្សាន្តល្បែងប្រជាប្រិយ។ គួរឲ្យចាប់អារម្មណបំផុតនោះ គឺការលេងដណ្តើមស្លឹកឈើនៅទីលានជិះឡានបុកគ្នា (Bumper Car)។ បបួលមិត្តភ័ក្តិនិងក្រុមគ្រួសារទៅលេងដណ្តើមស្លឹកឈើបែបថ្មីនេះទាំងអស់គ្នា! ទៅកាន់តែច្រើនបានសំបុត្របន្ថែមកាន់តែច្រើន ព្រោះ Bumper Car មាន promotion ទិញ ៣ថែម ១!

កាដូពិសេសរាល់៣ម៉ោងម្តង!!

កម្មវិធីចូលឆ្នាំខ្មែរនៅ Kids City ធានាថា សប្បាយ រំជើបរំជួល គ្រប់វិនាទី ! Kids City មានកាដូពិសេសជាច្រើនប្រកាសចែកជូន ដើម្បីពញ្ញាក់អារម្មណអតិថិជនទាំងអស់រាល់ ៣ ម៉ោងម្តង។

Promotion for Chatime!
Pick your Package:
$10 worth of Chatime GET 1 pass to Ice Park / Kids Park or,
2 Ice Park / Kids Park for a FREE drink of your choice at Chatime

ព្រោះស្នាមញញឹមខ្មែរ វិចិត្រករម្នាក់ សុខចិត្តលាស្រុកកំណើតមកគូរនៅខ្មែរ

Happy Paintings របស់ Stephane Delapreeបង្ហាញពី ស្នាមញញឹមរបស់ប្រជាជនកម្ពុជា

ពេលខ្លះអ្នកប្រហែលជាចាប់អារម្មណគំនូរមួយសេរីដែលគូរបែបរូបត្លុក ប្រើពណ៌ស្រស់ និងមានលក្ខណៈស្រដៀងគ្នាមួយគឺ រូបគំនូរទាំងនោះ សុទ្ធតែបង្ហាញនូវស្នាមញញឹម មិនថាមនុស្សក្នុងរូបគំនូរជា ព្រះសង្ឃ ក្មេង ចាស់ មិនថាពួកគេកំពុងប្រជ្រៀតគ្នាក្នុងឡាន ឬ ធ្វើស្រែចម្ការឡើយ មនុស្សក្នុងផ្ទាំងគំនូរទាំងនោះសុទ្ធតែមានស្នាមញញឹមស្រស់ស្រាយទាំងអស់។ គំនូរទាំងនេះ មានឈ្មោះថា Happy Cambodia ដែលគូរឡើងដោយ វិចិត្រករ Stephane Delapree។

Stephane Delapree ជនជាតិបារាំងនៅប្រទេស កាណាដា មកដល់ប្រទេសកម្ពុជាដំបូងនៅឆ្នាំ 1995 និងចាប់ផ្តើមបង្កើតសេរីផ្ទាំងគំនូរក្នុងឆ្នាំ 1997 ក្រោយពីការតាំងពិព័រណ៍លើកដំបូងរបស់គាត់មានឈ្មោះថា Happy Cambodia ដែលធ្វើឲ្យផ្ទាំងគំនូររបស់គាត់ត្រូវបានគេស្គាល់ថាជា Happy Paintings ជាផ្ទាំងគំនូរដែលបង្ហាញពីស្នាមញញឹម និងធ្វើឲ្យអ្នកមើល រំភើបចិត្តនិងញញឹមតាមនោះដែរ។

គំនិតសំខាន់នៃ Happy Paintings គឺ សុភមង្គល និង ភាពសមញ្ញានៃជីវិត។ Happy Cambodia ជាសេរី ផ្ទាំងគំនូរដែល Stephane Delapree គូរឡើងដើម្បីបង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដែលមើលតាមរយៈភាព សមញ្ញាបំផុតដូចមើលពីក្នុងកែវភ្នែករបស់ក្មេង ដែលបង្ហាញពីភាព ស្រស់ស្អាតដែល អ្នកគំនូរជនជាតិកាណាដារូបនេះ មើលឃើញក្នុងប្រជាជនខ្មែរទូទៅ។ “ ប្រជាជនខ្មែរមើលទៅស្លូតបូត ឆ្លាត សាមញ្ញ ហើយស្រស់ស្អាត “ Stephane Delapree និយាយ “ខ្ញុំស្រលាញ់កម្ពុជាណាស់”។ ស្នាដៃសិល្បៈនីមួយឆ្លុះបញ្ចាំងពីចរិតលក្ខណៈរបស់សិល្បករដែលបានបង្កើតស្នាដៃទាំងនោះឡើង។

Stephane Delapree បាននិយាយរៀបរាប់ប្រាប់ពី មូលហេតុដែលគាត់ប្រើប្រាស់តែ ពណ៌ស្រស់ និងមានស្នាមញញឹមថា វាបង្ហាញពីអត្តចរិតរៈ រាយនិងចូលចិត្តញញឹមរបស់គាត់ ដែលគាត់ចង់ចែករំលែក ជាមួយមនុស្សដទៃម៉្យាងដើម្បី បង្កើតផ្ទាំងគំនូរដែលបង្ហាញពីប្រទេសកម្ពុជានិងប្រជាជនផង។ ស្នាដៃរបស់ Stephane Delapree គឺ សេរី Happy Paintings ទទួលបាន

ការកោតសរសើរយ៉ាងលើសលប់ ដោយក្នុងនោះមានសារលិខិតថ្លែងអំណរគុណរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ផងដែរដែលពីកំឡុងឆ្នាំ 90 ។ ថ្មីៗនេះ Happy Paintings ក៏ត្រូវបានដាក់តាំងនៅក្នុងស្ថានទូតបារាំងនិងបានសម្ភាសដោយស្ថានីយទូរទស្សន៍រុស្ស៊ីផងដែរ។ ផ្ទាំងគំនូរ Happy Paintings អាចរកទិញបាន នៅ Happy Painting Gallery អគារ FCC តាមបណ្តោយមហាវិថីព្រះស៊ីសុវត្ថិ និងនៅជិត Pub Street ខេត្តសៀមរាប។

Happy Paintings by Stephane Delapree

From time to time you might notice these series of painting showing daily routine of Cambodia people though figurative motif in colorful shades. The most noticeable resemblance is probably the smiling faces that feature in every paintings. Whether it is a picture of a monk, or families, even if people were cramming in car, they are all smiling. These paintings are a series of “Happy Cambodia” paintings by Mr. Stephane Delapree.

Stephane Delapree, aka Stef, was born in Paris, France, grew up in Quebec Canada. Comes and goes to and from Cambodia, since 1995. He started Happy Painting Gallery since 1997, after many exhibitions in Sofitel Cambodiana, Inter-Contionental, Le Royal Raffles Hotels in Phnom Penh, and in Victoria Hotel, Princess Angkor Hotel, Angkor Century Hotel, FCC, to names some, in Siem Reap .

His first exhibition “Happy Cambodia” earned his art the name “Happy Paintings” and as been known as such ever since.

The concept of Happy Paintings is happiness and simplicity. Happy Cambodia, is a series of happy paintings depicting the everyday life in Cambodia, seen through a child's eyes. Happy Cambodia depicted everyday life of Cambodian people with smiles and vibrant color. It illustrates the beauty that Stef sees in Cambodian people. “They're are intelligent, kinds, simple, colorful, smiling and beautiful,” Stef said, “I love Cambodia.”

Clearly the art reflects a lot about the artist. According to Stef, all his painting has a little bit of himself in all his artwork. Though colors carries different meanings – were they meant to be dark or happy feelings – Stef's choice in vibrant painting speaks volume of his colorful personality. “I am a person who smiles a lot,” he said, “it is normal that smile is at the center of my art.”

When asked which one of his painting is his favorite, the answer is delightful as expected “All.”

Happy Paintings have been praised by many, including our highly respected, HRH Norodom Sihanouk in his thank you letter to Stef. Happy paintings also gain the priviledege of displaying 14 huge sizes paintings inside the French Embassy. Everyone loves Happy Painting, better get the orginal paintings now before the prize go up!

You can find Happy Paintings at “Happy Painting Gallery,” 363, Sisowath Quay (FCC building) and in Suem Reap, at the “Happy Cambodia Gallery” between Psar Chaas and Pub street.

Happy Paintings also has the exhibition of 14 huge sizes happy paintings, inside the French Embassy. Travellers can see my artworks in the “Ahuja Museum of Arts” in Mumbay, India, and soon at “Gnani art Gallery” in Singapore, and in Quebec, Canada.

MODEL: សុគា គីមលាង
STYLISH: Yulianna Bellini
PHOTO: Avaha Photography
093 887 171
avaha
PHOTOGRAPHY
WEDDING | PRE-WEDDING | FASHION | EVENT

MODEL: សុគា គីមលាង
STYLISH: Yulianna Bellini
PHOTO: Avaha Photography
093 887 171
avaha
PHOTOGRAPHY
WEDDING | PRE-WEDDING | FASHION | EVENT

MODEL: សុគា គីមលាង
PHOTO: Avaha Photography
093 887 171
avaha
PHOTOGRAPHY
WEDDING | PRE-WEDDING | FASHION | EVENT

Yulianna Stylist មកពីអឺរ៉ុប៖ « ខ្ញុំស្រលាញ់ស្នាមញញឹមបែបធម្មជាតិប្រជាជនខ្មែរ »

សម័យឥឡូវយើងសង្កេតឃើញថាខ្មែរយើងហ៊ានលេងម៉ូតសំលៀកបំពាក់មិនចាញ់ប្រទេសផ្សេងៗទេ។ យើងមើលខ្លួនឯងមិនដឹងឡើយថាមានការផ្លាស់ប្តូរយ៉ាងណាខ្លះឡើយក្នុងវិស័យម៉ូតនេះ ពាក់ព័ន្ធនឹងចំណុចនេះ Sabay Magz បានជួបជជែកគ្នាជាមួយនឹងលោកស្រី Yulianna Stylist មកពីអឺរ៉ុប មកបង្ហាញពីគំនិតផ្ទាល់ខ្លួនទៅលើការលេងម៉ូដរបស់អ្នកភ្នំពេញ។

Yulianna ជាអ្នករៀបចំម៉ូតសំលៀកបំពាក់ ចាប់ផ្តើមអាជីពក្នុងវិស័យនេះដំបូងជាតារាបង្ហាញម៉ូត ក្រោយមកទៀតចំណាយពេល៥ឆ្នាំ ធ្វើដំណើរទៅកាន់ប្រទេសនានាដូចជា បារាំង អ៊ីតាលី ជាដើម ដើម្បីសិក្សាពីម៉ូតសំលៀកបំពាក់ប្រទេសនានា។

អ្នករៀបចំម៉ូតសំលៀកបំពាក់មកពីប្រទេស អ៊ុយក្រែនរូបនេះ បានប្រាប់ Sabay Magz ថា៖ « ម៉ូតសំលៀកបំពាក់នៅប្រទេសខ្មែរប្លែកពីប្រទេសប៉ែកខាងអឺរ៉ុបខ្លាំងមែនទែន ចំណុចពិសេសដែលខ្ញុំសរសើរដោយស្មោះនោះ គឺការប្រើប្រាស់ ពណ៌ ប្រភេទក្រណាត់ ក្នុងលក្ខណៈស្រគត់ស្រគំតែបែបស៊ីវិល័យ និយាយទៅរៀបចំម៉ូតខោអាវខុសពីអ្វីដែលខ្ញុំធ្លាប់បានឃើញពីមុនមក »។

បន្ថែមពីនេះ Stylist ជនជាតិអឺរ៉ុបរូបនេះលើកហេតុផលមួយទៀតថា ប្លែកតែបន្តិចពេលឃើញមនុស្សច្រើនពាក់អាវគេងយប់ដើរពេញទីក្រុងនៅពេលព្រឹកព្រលឹម តែដល់ពេលល្ងាចៗ ឡើងទើបឃើញមនុស្សម្នា ក្មេងៗស្លៀកពាក់ស្អាតបាតដើរលេងមើលទៅស៊ីវិល័យមែនទែន ។

Yuliannaបានរៀបចំ ជ្រើសរើស ម៉ូតសំលៀកបំពាក់សម្រាប់ការថតដាក់ផ្សាយលើទស្សនាវដ្តីជាច្រើន កំឡុងរយៈពេល៦ខែដែលបានស្នាក់នៅប្រទេសកម្ពុជា ប៉ុន្តែក្រៅពីនេះ Yulianna ចូលចិត្តលេងលាយម៉ូតសំលៀកបំពាក់ច្រើន ប្លែកៗ ចូលគ្នា។ Yulianna និយាយថាស្រុកខ្មែរមានឥវ៉ាន់ប្លែកៗ ច្រើន ក្នុងតម្លៃថោកសមរម្យ សាកសមបំផុតសម្រាប់នរណាចូលចិត្តលេងម៉ូតសំលៀកបំពាក់ឬ ចង់ស្វែងរក style មួយសម្រាប់ខ្លួនឯងមួយ។

ពេលសួរថារបស់តំណាងភាពស្រគត់ស្រគំ ទន់ភ្លន់ សុភាពរាបសារផុសចេញពីស្នាមញញឹមដែលដែលប្រជាជនខ្មែរមាន Yulianna ពេញចិត្តនឹងយកមកថតលាយនឹងការថតបង្ហាញម៉ូត គឺ Yulianna ជ្រើសរើសផ្កាឈូក ដោយបកស្រាយថាផ្កាឈូកមានរូបរាងប្លែកពីផ្កាដទៃ និងមានភាពថ្លៃថ្នូរបំផុត។ Yulianna បន្ថែមជាចុងក្រោយថា ប្រទេសកម្ពុជាមាន សម្បត្តិធម្មជាតិស្រស់បំព្រង ដូចឋានសួគ៌ទៅហើយ ដែលនេះជារបស់បន្ថែមលើការ ថតម៉ូតមិនអាចទៅរកឯណាបានទៀតទេ។

Yulianna បានចាប់ផ្តើមចូលរួមធ្វើការងារជាមួយ Sabay Magz ក្នុងខែមេសានេះ។ អ្វីដែល Yulianna និង Sabay Magz បង្ហាញលើទំព័រ Fashion លេខទី ៣៥ នេះ គឺស្នាមញញឹមដែលផុសចេញពីធម្មជាតិពិតៗរបស់យុវតីខ្មែរ។ មិត្តអ្នកអាននឹងបានឃើញស្នាមញញឹមដែលក្រុមការងារបានធ្វើការរួមគ្នានេះនៅទំព័របន្ទាប់៕

អត្ថបទ៖ រ៉ូលីន

Insight on Cambodians' Fashion
Through the eyes of a Stylist

Fashion in Cambodia is taking its baby step – you see people try more variety of styles and be a bit more open-minded toward the dress code. We might not notice the subtle changes we go through everyday, let's hear about our fashion sense thought a fashion stylist's point of view!

Yulianna is a stylist from Ukraine, whose passion in fashion started as an amateur model. Now she's a fashion stylist who travel the world - France, Italy, to name a few – to learn more about this sophisticated ever changing industry. Traveling to Cambodia for the first time, Yulianna shared her experience (fashion-wise) about Cambodia:

"Fashion sense of Cambodia looks particular for me because it is different from anything you can see in Europe," said Yulianna. There's a positive "different" Yulianna sees in the different kind of colors, cuts and approaches of Cambodians' fashion "It is a bit strange though," Yulianna added, "to see so multiple people wearing pajamas in the streets of the city in the morning, but closer to the dawn situation changes and many beautifully dressed girls and boys start coming out."

During her six-month stay in Cambodia, Yulianna had been working for many magazine photo shoot and take pleasure in experimenting with many styles. Cambodia is the perfect place for those who hasn't found a style yet and need to try a lot of new things. "Looks like it almost free of charge here - to change styles in clothes, accessories, haircuts and even to change the color of your eyes for a while! You have a chance here, because it is exactly what a person, who hasn't find own style needs - to try as many as possible to make the right choice."

When asked what Cambodian iconic piece Yulianna would pick for a very sophisticated photo shoot, she delightfully said "Lotus", claiming to be the most miscellaneous and sophisticated flower in the World. "Khmer people live in Paradise on Earth", said Yulianna. Besides the style in clothes we wear, Cambodia's nature is actually the most precious art that encourage Yulianna to create more beautiful pictures.

Yulianna teamed up with Sabay Magz for this issue Fashion shoot. What shown on this #35 issue is a sweet genuine smile of a Cambodian girl and her country's vibrant nature combined to make this fashion shoot truly bloom.

ហោរាសាស្រ្ត ប្រចាំខែមេសា ២០១៥

HOROSCOPE FOR APRIL 2015



ឆ្នាំជូត Rat
មុននឹងធ្វើអ្វីមួយក្នុងខែនេះអ្នកត្រូវគិតឲ្យបានល្អិតល្អន់ជាពិសេសព្រោះអាចមានគ្រោះ ត្រូវមិត្តជិតស្និតឆបោកបាន។

Rethink everything before you make any investment plans. You might be in danger if being fraud by a close friend.

ឆ្នាំរោង Dragon
រាល់ការងារនានាដែលអ្នកបានខិតខំព្យាយាមធ្វើរាប់ខែមកនេះ កំពុងដំណើរការទៅមុខយ៉ាងរលូន ធ្វើឲ្យអ្នកមានអារម្មណ៍ល្អហើយមានសុទិដ្ឋិនិយមខ្លះក្នុងជីវិត។
The project you have been working on is looking good and it's going to the direction you want. Your spirit is high and you're incredibly optimistic!

ឆ្នាំវក Monkey
អ្នកមានភាពនឿយហត់ជាខ្លាំង ដោយមានកង្វល់លើរឿងជាច្រើន មិនថាតូចមិនថាធំ។ គួរតែសម្រាកខ្លះទៅ ដើម្បីខ្លួនឯងសប្បាយចិត្តជាងមុន នេះក៏ល្អម្យ៉ាងដែរសម្រាប់អ្នកជុំវិញខ្លួនព្រោះបើអ្នកមិនសូវនឿយអ្នកក៏មិនរករឿង
You're probably to concerned over everything and that is wearing you out. Take a step back and have some time to yourself. Would do you and the ones you been lashing on a favor.



ឆ្នាំឆ្លូវ Ox
មិនថាការសិក្សាឬការងារឡើយ អ្នកគ្មានអារម្មណ៍ដើម្បីធ្វើការទាំងនោះទេ។ បញ្ហាក្នុងគ្រួសារនិងមិត្តកំពុងធ្វើឲ្យអ្នកពិបាកចិត្ត នឹកធ្វើអ្វីមិនចេញ។

Whether it's your study or your work you need to pay attention. Friends or family problem is effecting you so much you're losing focus.

ឆ្នាំម្សាញ់ Snake
មើលទៅរាសីអ្នកផ្នែកហិរញ្ញវត្ថុសម្រាប់ខែនេះមិនសូវល្អសោះ អារម្មណ៍មិនល្អ ចំពោះបញ្ហានេះទៀតសោតធ្វើឲ្យជីវិតគូស្នេហ៍មានការរកាំរកូស។ ធ្វើចិត្តឲ្យត្រជាក់ខ្លះទៅ ទំនាស់ក្នុងរឿងស្នេហាលើកនេះអាចឲ្យអ្នកស្តាយក្រោយបាន។Your finance is not looking good and that is affecting how you treat your lover. Take a deep breathe, or you might regret fighting with her on this one.



ឆ្នាំរកា Rooster
ឆ្នាំរកខែនេះចំណាយធំជាងចំណូលឆ្ងាយណាស់! ល្អមរៀបផែនការចាយវាយខ្លះទៅ ហើយរៀបពីដើមខែតែម្តងកាន់តែល្អ មិនអីចឹងទេប្រយ័ត្នគ្មានលុយក្នុងហោប៉ៅចាយដាច់ខែ!

Your expense is overwhelming. You need a serious budget plan right from the start of the month, or else you'll never gonna make it through the month!

ឆ្នាំខាល Tiger
អ្នកប្រឹងប្រែងធ្វើការក្រោមសម្ពាធ ហើយប្តេជ្ញាថានឹងធ្វើការឲ្យបានល្អប្រសើរបំផុត។ សំណាងល្អក្នុងការងារតែកុំភ្លេចមើលថែសុខភាពខ្លួនឯងផង។

You're working great under pressure to achieve the best result, good luck on your work but don't forget to rewind or else you're just hurting yourself.

ឆ្នាំមមី Horse
រាសីឡើងខ្ពស់ត្រដែតក្នុងរឿងស្នេហា! ជីវិតគូស្នេហ៍របស់អ្នកមើលទៅផ្អែមល្ហែម គូរស្នេហ៍មានការយល់ចិត្តគ្នាល្អណាស់ ។
Your relationship with your beloved is truly passionate, it's sparkles! You truly understand what each other wants and needs and happily compliment each other.

ឆ្នាំច Dog
ខែនេះអ្នកមានអារម្មណ៍ល្អខុសពីធម្មតា ចេះលេងសើចច្រើន ចំណែកការងារក៏ខិតខំប្រឹងប្រែងអស់ពីសមត្ថភាពទៀតផង! គ្មាននរណាប្រជែងនឹងអ្នកបានឡើយ!

One might say your spirit for work is high! Your humor is charming and your work is incontestable. Career is surely blooming the direction you wanted it to be.



ឆ្នាំថោះ Rabbit
ខែនេះអ្នកមានសុខភាពមិនសូវល្អទេ។ មួយរយៈនេះ អ្នកព្យាយាមធ្វើការងារហួសកម្រិត ហើយនូវឆ្អៀតលុកដៃ ខ្វាយខ្វល់ពីរឿងអ្នកដ៏ទៃទៀត។ល្អមដល់ពេលសម្រាកហើយគិតពីខ្លួនឯងខ្លះទៅ។
Your health is degrading slowly. It's a very heated month ahead so take extra care of yourself! You been biting off more than you can chew, so now its the time to relax and have some time to yourself.

ឆ្នាំមមែ Goat
រាសីធ្លាក់ចុះ។ អាចមានរឿងរកាំរកូសជាមួយមនុស្សជាទីស្រលាញ់មិនថាជាគ្រួសារ មិត្តភក្តិ ឬ សង្សារ។
Your luck in relationship is not running low. You're in harmony with both your family, friends and lovers.



ឆ្នាំកុរ Pig
ផែនការរបស់អ្នកក្នុងការរកស៊ី មុខជំនួញឬការងារផ្សេងៗ អាចនឹងមើលទៅដូចជាមិនទៅមុខ ឬអាចជួបការខកខានឱកាសនានា។ប៉ុន្តែកុំបារម្ភអី ដល់ពេលលំបាក អ្នកនឹងទទួលបានជំនួយពីអ្នកជុំវិញខ្លួន ។
Your plan in business or at workplace is at a standstill. Don't panic. With your friendly aura, you would get the help you need.

Photo : **AVAHA PHOTOGRAPHY**
Talent : **CHAM NOU**

សិល្បៈ SHOWOFF

ផ្ញើរ Art-Work របស់អ្នកតាមរយៈអ៊ីម៉ែល : luok.vannrong@cidc.com.kh ។
ក្រុមការងារនឹងធ្វើការជ្រើសរើស Art-Work របស់អ្នកក្នុងករណីសបស្រមតាមលក្ខខណ្ឌដែលបានកំណត់។ ព័ត៌មានបន្ថែម សូមចូលទៅកាន់ទំព័រហ្វេសបុក Facebook Sabay Magz : https://www.facebook.com/SabayMagz។

ប្រធានបទ៖ LAND OF GOD | **ប្រភេទ៖** Digital ART | **សិល្បៈករ៖** Norou Legendz | **ទីក្រុង៖** បាត់ដំបង

ប្រភេទ៖ Digital ART | **សិល្បៈករ៖** Sin Vandy | **ទីក្រុង៖** បាត់ដំបង

មហាសង្ក្រាន្តនៅប្រទេសថៃគេធ្វើអ្វីខ្លះ ?

ដូចគ្នានឹងប្រទេសកម្ពុជាដែរ មហាសង្ក្រាន្តជាការប្រារព្ធអបអរសាទរបុណ្យចូលឆ្នាំថ្មី។ នៅប្រទេសថៃ។ ការប្រារព្ធ ពិធីបុណ្យចូលឆ្នាំថ្មីមាន រយៈពេល៣ថ្ងៃដែរ គិតចាប់ពីថ្ងៃទី១៣ខែមេសា។ ថ្ងៃដំបូងនៃបុណ្យចូលឆ្នាំថ្មីនេះ គេទៅលេងបងប្អូន ជីដូន ជីតា និង ចាក់ទឹកមន្តដែលមាន លាយផ្កា និងទឹកអប់ផ្សេងៗ លើបាតដៃដើម្បីទទួលបានសេរីសួស្តីឆ្នាំថ្មី។

CHONTICHA PRIN

កាលពីមុន ក្នុងមហាសង្ក្រាន្តឆ្នាំថ្មីគេនិយមទៅលេងបាចទឹក និងពូនភ្នំខ្សាច់នៅវត្ត ប៉ុន្តែបច្ចុប្បន្ន ទំនៀមទម្លាប់នេះត្រូវបាន ផ្លាស់ប្តូរ ក្លាយអស់ទៅហើយព្រោះយុវវ័យគេចូលចិត្តធ្វើអ្វី ដែលសប្បាយជាងនេះ។

គេលេងសប្បាយឆ្លងឆ្នាំថ្មីនៅប្រទេសថៃ ដោយលេងបាចទឹក តែមិនមែនបាច់ទឹកធម្មតាទេ គឺបាចទឹកធុងធំៗ ពីព្រឹកទល់ ល្ងាចតែម្តង! ពីម៉ោង ១១ថ្ងៃ ត្រង់ដល់ ៧ល្ងាច! នេះទោះបី ជាអាកាសធាតុក្តៅយ៉ាងណាក៏ត្រជាក់ខ្លួនដែរទម្រាំបាចទឹក រួច! ខ្ញុំធ្លាប់បានទៅលេងបាចទឹកនៅប្រទេសថៃឆ្នាំមុន ហើយ វាពិតជាសប្បាយមែន ពិសេសពេលឃើញគេទទឹកខោអាវ ដោយសារយើង! អ្នកជិតខាងដែលនៅក្បែរនោះ បើកបង្អួច ចាក់ចម្រៀងលឺៗទៀតផង ហើយគ្រប់គ្នាឡើងរាំពេញនឹងតែម្តង ។

ក្រោយពីបាចទឹកហើយ យើងក៏និយាយពាក្យជូនពរឆ្នាំថ្មីដែរ ហើយពេលខ្លះទៀតពេល បុរស ឃើញនារីស្អាតៗ គេចូលចិត្តយកម្សៅទៅបាតថ្ពាល់ ប៉ុន្តែកុំបន្លំឲ្យសោះប្រយ័ត្នត្រូវ ប៉ូលិសផាក ៥០០បាត!
មហាសង្ក្រាន្តនៅស្រុកថៃមានប្រជាប្រិយភាពណាស់ ហើយធានាថាមិនរួចខ្លួនទេត្រូវតែ ទទឹកតែម្តង! គេលេងមហាសង្ក្រាន្តនេះ មិនមែនតែតាម២-៣ផ្លូវទេ អ្នកស្រុកថៃប្រហែល ៨០% ចូលរួមលេងក្នុងពិធីមហាសង្ក្រាន្តឆ្នាំថ្មី មួយឆ្នាំៗ។

មហាសង្ក្រាន្តក៏ត្រូវបានប្រារព្ធនៅប្រទេសឡាវដែរ តែបើតាមបទពិសោធន៍ធ្លាប់បានទៅ លេង គេមិនសូវធ្វើអីអោយ អធិកអធម និងលេងច្រើនដូចនៅថៃទេ។ បរទេសភាគច្រើន ចូលចិត្តមហាសង្ក្រាន្តនៅថៃជាង។

Songkran festival in Thailand,Thai new year , is celebrated for 3 days. The first day is 13th April, we will go visit our grandparents for wish them happy new year and we will pour water to their hands and wish them well, in this water we will filled some flower or some fragrant but it's a special fragrant it's smell very good like you're in spa doing some massage (hahaha).

In the past long time ago in Songkran festival we went to a temple around our house to splash water in there and build something by sand. It was very nice traditional. but nowadays this traditional had changed because we have many teenager would like to do more fun but we still keep this traditional.

After this celebration we will have a fun time, going to some places to splash water and not some water! but it's a big tank of water on a pickup car or walking on a street. We're going to do it all day start at 11 a.m. until 6-7 p.m. after this time we might be cold If the weather is pretty hot, I'm sure many people would like to do this all day long. I went for this last year and i can't stop it because it was very fun to see some other people got wet by me (hahahaha) and many houses near a street they will open a loudly song and people around start to dance.

When we're on a street to play Songkran festival, we splash water to them and also wish them to happy new year. some man when he saw a woman who is beautiful or he would like to flirt, He will go in front of her and apply power on her face (hahaha many man love it) but don't do something nudity, a police will arrested you and fine 500baht.

Songkran day is very popular in Thailand if you go out these days you will wet I swear. I think many people love to play in Thailand, we have a huge festival along street but it's not only 2-3 streets in Thailand but It's 80 percent that they play Songkran festival.
I saw Songkran festival in Laos but they don't play crazy like us so that why many foreigners would like to join us.

ចំណុច ៦ យ៉ាង ធ្វើឲ្យអ្នកស្គាល់ទីក្រុងហាណូយកាន់តែច្បាស់

Text by:
Chrin Samvisal
បច្ចុប្បន្នកំពុងធ្វើការនៅទីក្រុង ហាណូយ
ជាអ្នកបកប្រែកម្មវិធីទូរសព្ទជាភាសាខ្មែរ

ពេលដែលលឺពាក្យថា "ហាណូយ" អារម្មណ៍របស់យើងមានឆ្លើយតបមកវិញថា "អូទីក្រុងរបស់ វៀតណាម" ។ ពេលខ្លះយើងឆ្ងល់ថាតើទិដ្ឋភាព ប្រជាជន វប្បធម៌ ភាពជឿនលឿន ការកម្សាន្តនៅក្នុងទីក្រុងនោះមានលក្ខណៈដូចម្ដេចដែរ? "យ៉ាងម៉េចទៅទីក្រុងប្រទេសគេ? ធ្លាប់តែលឺគេនិយាយតគ្នា។" ថ្ងៃនេះ សប្បាយនឹងនាំប្រិយមិត្តទៅទស្សនាទិដ្ឋភាពទីក្រុងហាណូយ ដែលជារាជធានី និងទីក្រុងវប្បធម៌មានអាយុកាលជាង ១០០០ ឆ្នាំ របស់ប្រទេសវៀតណាម ទាំងអស់គ្នា។

១.ស្នាន់តែតារា K-pop!

ឥទ្ធិពលវប្បធម៌សម័យទំនើបរបស់ប្រទេសកូរ៉េ មានឥទ្ធិពលយ៉ាងខ្លាំងលើយុវជននៅក្នុងទៅហាណូយ។ នៅតាមដងផ្លូវយើងសង្កេតឃើញរបៀបនៃការតុបតែង និងរាងរៅរបស់ពួកគេមិនចាញ់តារាអាជីពកូរ៉េប៉ុន្មានឡើយ។ មិនត្រឹមតែយុវជនទូទៅទទួលយកវប្បធម៌នេះយ៉ាងពេញទំហឹងទេ តែតារាចម្រៀងសម័យទំនើបវៀតណាមក៏បង្កើតស្នាដៃសិល្បៈដែលបង្ហាញពីឥទ្ធិពលនេះផងដែរ។

២. ទីក្រុងកាហ្វេ

ហាណូយមានភាពល្បីល្បាញលើរសជាតិ និងភាពសំបូរបែបនៃកាហ្វេរបស់ខ្លួន។ អ្នកអាចស្វែងរកហាងកាហ្វេបានស្ទើរតែគ្រប់ទីកន្លែងទាំងអស់នៅក្នុងទីក្រុងនេះ។ ហើយវាមានលក្ខណៈខុសប្លែកបន្តិចពីកាហ្វេនៅក្នុងប្រទេសកម្ពុជា។ នៅពេលដែលអ្នកកុម្ម៉ង់កាហ្វេ អ្នកនឹងទទួលបានកាហ្វេដែលមានចំណុះត្រឹមកន្លះកែវប៉ុណ្ណោះ ដែលនោះជាវប្បធម៌របស់ប្រជាជននៅក្នុងតំបន់នេះ។ ប្រជាជននៅទីនោះចូលចិត្តផឹកកាហ្វេ និងតែនៅតាមទាម និងហាងកាហ្វេតូចៗនាពេលទំនេរ។ បន្ថែមពីនេះ អ្នកក៏អាចសាកល្បងរសជាតិកាហ្វេពងមាន់ និងកាហ្វេដូងផងដែរ។ ចង់សាកល្បងដែរទេ?

៣.មិនចាំបាច់ប្រើម៉ាស៊ីនត្រជាក់ទេ!

នៅទីក្រុងហាណូយមានរដូវកាលធំៗ ៤ ដែលរួមមានរដូវរងា រដូវក្ដៅ រដូវស្លឹកឈើជ្រុះ និងរដូវផ្ការីក ។ រដូវដែលខ្ញុំចូលចិត្តជាងគេគឺរដូវរងា នៅអំឡុងពេលនេះព្រះអាទិត្យគ្រប់ដណ្ដប់ដោយពពកស្ទើរតែ ២៤ ម៉ោង ដែលធ្វើឲ្យផ្ទៃមេឃមានភាពស្រទំជានិច្ច។ អាកាសធាតុអាចធ្លាក់ដល់ ៧ អង្សា ដូច្នេះអ្នកអាចធ្វើដំណើរបានឆ្ងាយដើម្បី គយគន់ទេសភាពនៅក្នុងរាជធានីនេះដោយគ្មានភាពនឿយហត់។

៤. សាកល្បងម្ហូបពិសេសៗជាមួយគ្នា

អាហារដែលនិមិត្តសញ្ញាប្រទេសវៀតណាមគឺហ្វឺ។ អ្នកអាចស្វែងរកវាបាននៅគ្រប់ទីកន្លែង។ វាក៏ត្រូវបានឆ្នៃប្រឌិតធ្វើឲ្យមានលក្ខណៈខុសៗគ្នាទៅតាមអ្នកលក់ផងដែរ។ ក្រៅពីនេះអ្នកក៏អាចញ៉ាំប៊ូនឆា និងប៊ូនដែលមានលក្ខណៈស្រដៀងនឹងនំបញ្ចុក។ ប្រសិនបើអ្នកគិតថាចង់សាកអ្វីដែលប្លែកជាងនេះទៀត អាចសាកល្បងញ៉ាំបាយដំណើបជាមួយសាច់ក្រក និងសាច់ផាត់ផងដែរ។

៥.ទិញរបស់បានច្រើនជាងមុន!

នៅពេលដែលអ្នកចូលទិញទំនិញនៅក្នុងម៉ាតអ្នកនឹងមានអារម្មណ៍ថាវាមានតម្លៃថោក ពីព្រោះរដ្ឋាភិបាលវៀតណាមព្យាយាមការពារទំនិញក្នុងស្រុករបស់ពួកគេ។ ឧទាហរណ៍ដូចជា ប៊ិចស៊ីមួយដបតូចមានតម្លៃត្រឹមតែ ១០០០ រៀលប៉ុណ្ណោះ តែវាមានតម្លៃពី ២០០០ រៀលនៅប្រទេសយើង។ និយាយរួមមកសម្ភារៈផ្សេងដែលផលិតក្នុងស្រុកគឺមានតម្លៃថោក។ ផ្ទុយមកវិញ ប្រសិនបើអ្នកទិញទំនិញនាំចូល នោះអ្នកនឹងសង្កេតឃើញថាវាមានតម្លៃថ្លៃ ហើយអាចនឹងថ្លៃខ្លាំង!

៦.ម៉ូតូ ម៉ូតូ ម៉ូតូគ្រប់ទីកន្លែង

អ្នកនឹងឃើញចំនួនម៉ូតូដ៏ច្រើនលើសលុបនៅក្នុងទីក្រុងនេះ។ ដែលវាជាមធ្យោបាយធ្វើដំណើរដ៏សាមញ្ញ និងសំខាន់បំផុតសម្រាប់ប្រជាជនទូទៅ។ ដោយសារវាមានតម្លៃសមស្រប ដែលអនុញ្ញាតឲ្យប្រជាជននៅទីនោះ។ ប្រសិនបើអ្នកមានរថយន្ត អ្នកគឺជាអ្នកមានណាស់ហើយមើលទៅ ពីព្រោះរដ្ឋាភិបាលបានកំណត់ពន្ធ ២០០% លើយានយន្តដែលបាននាំចូលទាំងអស់។ ដូច្នេះប្រសិនបើរថយន្តរបស់អ្នកមានតម្លៃ ៥ ម៉ឺនដុល្លារ នោះតម្លៃសរុបរបស់ឡាននោះគឺ ១៥ ម៉ឺនដុល្លារ។ ចុះចំពោះមធ្យោបាយដឹកជញ្ជូនសាធារណៈវិញ? អ្នកអាចប្រើប្រាស់សេវារថយន្តក្រុង តាក់ស៊ីដែលមានតម្លៃសមរម្យ និងម៉ូតូឌុបផងដែរ (ប៉ុន្តែមិនសូវមានម៉ូតូឌុបនៅទីនោះទេ)។

FRESH
YOUNG
VIBRANT

Scan here: for latest news updates

ថ្មី
យុវវ័យ
រស់រវើក
sabay.com.kh